**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royal de Droit et des Science Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# រឿងក្តីរដ្ឋប្បវេណីសម្រាប់សាលាដំបូងកម្ពុជា
# (ផ្តោតទៅលើការសរសេរពាក្យបណ្តឹង)

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ក.ឌីប៉ូ សូរិយ៉ា**

**រួម វិចិត្រា**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ហាប់ ផល្លី**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ឆ្នាំចូលសិក្សា ២០១៧

ជំនាន់ទី ២១

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ-នាងខ្ញុំ ជានិស្សិតកម្រិតឆ្នាំទី៤ ថ្នាក់បរិញ្ញាប្រនីតិសាស្ត្រ ជំនាន់ទី២១ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ក្នុងឆ្នាំសិក្សា ២០១៨-២០២១។ ខ្ញុំបាទ-នាងខ្ញុំ សូមថ្លែងអំណរគុណ និង ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

**លោកឪពុក និងអ្នកម្តាយ** ដែលជាអ្នកមានគុណក្នុងការលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត ញើសស្រស់ឈាមស្រស់ក្នុងការចិញ្ចឹមបីបាច់ ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ លើកទឹកចិត្ត និង ផ្គត់ផ្គង់ដល់ការរៀនសូត្រមកដល់ថ្ងៃនេះ ដោយគ្មានឡើយនូវពាក្យត្អូញត្អែរ។ ចំពោះមហាគុណរបស់លោកទាំងពីរ គឺកូននឹងកត់ទុកក្នុងចិត្តរបស់កូនជាអមតៈ និង ជូនពរលោកអ្នកមានគុណទាំងពីរសុខភាពល្អ អាយុយឺនយូរ ដើម្បីជាម្លប់ដល់កូនចៅតទៅជានិច្ចនិរន្តរ៍។

សាកលវិទ្យាធិការ **ឯកឧត្តមបណ្ឌិត លុយ ចន្ទ្រា** និង សាកលវិទ្យាធិការរង ព្រមទាំងព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និង លោក លោកស្រីសាស្ត្រាចារ្យ សហការី ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ ខិតខំយ៉ាងពេញទំហឹងក្នុងការបង្ហាត់បង្រៀន និង ណែនាំ ចង្អុលបង្ហាញទៅលើស្ថានភាពជាក់ស្តែង ដើម្បីឱ្យការសិក្សារបស់យើងខ្ញុំប្រព្រឹត្តិទៅបានយ៉ាងប្រសើរ។

ជាពិសេស ចំពោះ **សាស្ត្រាចារ្យ បណ្ឌិត ហាប់ ផល្លី** ដែលជាសាស្ត្រាចារ្យប្រកបដោយគតិបណ្ឌិត ដែលជានិច្ចជាកាលតែងតែលះបង់នូវកម្លាំងកាយ កម្លាំងចិត្ត ក្នុងការជួយជ្រោមជ្រែង បណ្តុះបណ្តាល ផ្ទេររាល់គំនិតនិងចំណេះដឹង ជួយកែសម្រួលរាល់កំហុសដែលមានក្នុងការស្រាវជ្រាវ ព្រមទាំងចែករំលែកនូវបទពិសោធន៍ក្នុងការស្រាវជ្រាវជាច្រើនដល់ខ្ញុំបាទ-នាងខ្ញុំ។

ជាចុងបញ្ចប់ ខ្ញុំបាទ-នាងខ្ញុំ សូមគោរពបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ តាមជួយថែរក្សាដល់ **លោកឪពុក អ្នកម្តាយ ឯកឧត្តម សកលវិទ្យាធិការ លោក លោកស្រី សាស្ត្រាចារ្យទាំងអស់** ជាពិសេសសាស្ត្រាចារ្យណែនាំផ្ទាល់ សូមឱ្យមានសុខភាពល្អពេញលេញបរិបូណ៌ ជួបប្រទះតែសេចក្តីសុខសេចក្តីចម្រើន វិបុលសុខ សុភមង្គល និងទទួលជោគជ័យរាល់ការងារ ភារកិច្ចទាំងអស់។

ភ្នំពេញ. ថ្ងៃទី ខែ ឆ្នាំ២០២១

**សូមអរគុណ**

# អំណរគុណ

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាលើជំនាញនីតិសាស្ត្រអស់រយៈពេល ៤ ឆ្នាំកន្លងមកនេះ ខ្ញុំបាទ-នាងខ្ញុំ យល់ឃើញថា នីតិសាស្ត្រជាជំនាញមួយដែលសំខាន់ក្នុងការជំរុញឱ្យសង្គមទាំងមូលទទួលបាននូវភាពសុខសាន្ត រីកចម្រើនដើរទៅមុខបានយ៉ាងរលូន។ អ្វីដែលពិសេសចំពោះមុខវិជ្ជានីតិវិធីរដ្ឋប្បវេណី គឺជាមុខវិជ្ជាមួយដែលខ្ញុំទាំងពីរនាក់បានសិក្សា និង ចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងចំណោមមុខវិជ្ជាទាំងអស់ ដែលជាហេតុនាំឱ្យខ្ញុំទាំងពីរនាក់ជ្រើសរើសប្រធានបទមួយដែលទាក់ទងនឹងមុខវិជ្ជានេះ យកមកចងក្រងធ្វើជាសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំទាំងពីរ ក្រោមប្រធានបទស្តីពី **រឿងក្តីរដ្ឋប្បវេណីសម្រាប់សាលាដំបូងកម្ពុជា៖ ផ្តោតទៅលើការសរសេរពាក្យបណ្តឹង** ដែលមានការផ្តួចផ្តើមគំនិត ណែនាំ និង ដឹកនាំយ៉ាងយកចិត្តទុកដាក់ពី បណ្ឌិតសាស្ត្រាចារ្យ **ហាប់ ផល្លី**។

ជាក់ស្តែង ការសរសេរ ការរៀបចំ និងការស្រាវជ្រាវសារណាមួយនេះ ត្រូវបានតាក់តែងឡើងដោយយោងតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី និង ឯកសារគតិយុត្តមួយចំនួនទៀតដែលពាក់ព័ន្ធ។សារណាមួយនេះ ត្រូវបានចងក្រងឡើងមកក្នុងគោលបំណងកសាងទុកជាឯកសារសម្រាប់និស្សិតទាំងឡាយណាដែលត្រូវការការស្រាវជ្រាវបន្ថែម អាចយកឯកសារមួយនេះប្រើប្រាស់ជាកម្មវត្ថុនៃការស្រាវជ្រាវបន្តទៀតបាន។

ខ្ញុំបាទ-នាងខ្ញុំ រំពឹងទុកយ៉ាងខ្លាំងថា ប្រធានបទស្តីពី **រឿងក្តីរដ្ឋប្បវេណីសម្រាប់សាលាដំបូងកម្ពុជា៖ ផ្តោតទៅលើការសរសេរពាក្យបណ្តឹង** នេះនឹងអាចជាចំណែកមួយដ៏សំខាន់សម្រាប់ជំនួយដល់និស្សិត និង អ្នកស្រាវជ្រាវគ្រប់រូប ក្នុងការយកសារណាមួយនេះធ្វើជា មូលដ្ឋាន និង បន្ថែមការយល់ដឹងឱ្យកាន់តែច្បាស់អំពី ការរៀបចំ ការសរសេរ និង ការអនុវត្តបណ្តឹងរដ្ឋប្បវេណីសម្រាប់សាលដំបូង ដោយផ្អែកតាមគោលការណ៍ចម្បងៗ ដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទនេះផងដែរ ខ្ញុំបាទ-នាងខ្ញុំ ក៏សុំធ្វើការរំលឹកគុណដល់សាស្ត្រាចារ្យ និង ស្ថាបនិកគ្រប់រូប ដែលបានបូជាទាំងកម្លាំងកាយ កម្លាំងចិត្តក្នុងការបង្កើតឱ្យមានច្បាប់នានាសម្រាប់ប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ជាពិសេសនោះគឺ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីជាប្រយោជន៍សម្រាប់វិស័យ យុត្តិធម៌ ក្នុងគោលបំណងទទួលបាននូវ សន្តិសុខ ស្ថេរភាព និង សុខុមាលភាពក្នុងសង្គម។

ខ្ញុំបាទ-នាងខ្ញុំ នឹងរង់ចាំទទួលនូវការរិះគន់ ស្ថាបនា កែលំអ និង ផ្តល់ការអនុគ្រោះនូវរាល់កំហុសឆ្គងដោយអចេតនាពីសំណាក់សាស្ត្រាចារ្យ មិត្តនិស្សិត និង អ្នកស្រាវជ្រាវជានិច្ច។

ភ្នំពេញ. ថ្ងៃទី ខែ ឆ្នាំ២០២១

**សូមអរគុណ**

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............ ១
**១.លំនាំបញ្ហានៃការស្រាវជ្រាវ** ............ ១
**២.បញ្ហានៃការស្រាវជ្រាវ** ............ ១
**៣.គោលបំណង និង សារៈសំខាន់នៃការស្រាវជ្រាវ** ............ ១
**៣.១.គោលបំណងនៃការស្រាវជ្រាវ** ............ ១
**៣.២.សារៈសំខាន់នៃការស្រាវជ្រាវ** ............ ២
**៤.វិធីសាស្ត្រនៃការស្រាវជ្រាវ** ............ ២
**៥.កម្រិតនៃការស្រាវជ្រាវ** ............ ២
**៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ............ ២

## ជំពូកទី១
## សញ្ញាណនៃរឿងក្តីរដ្ឋប្បវេណី

**១.១.ភាគី** ............ ៣
១.១.១.អត្ថន័យនៃភាគី ............ ៣
១.១.២.ដើមចោទ ............ ៣
១.១.៣.ចុងចម្លើយ ............ ៣
**១.២.តុលាការ** ............ ៤
១.២.១.សមត្ថកិច្ចតុលាការ ............ ៤
១.២.២.តួនាទីចៅក្រមក្នុងរឿងក្តីរដ្ឋប្បវេណី ............ ៥
១.២.៣.តួនាទីក្រឡាបញ្ជីក្នុងរឿងក្តីរដ្ឋប្បវេណី ............ ៦
១.២.៤.ការចូលរួមរបស់តំណាងអយ្យការ ............ ៦
**១.៣.មេធាវីតំណាងដោយអាណត្តិ** ............ ៦
១.៣.១.ការទទួលបានសិទ្ធិតំណាងដោយអាណត្តិ ............ ៧
១.៣.២.សិទ្ធិ និង កាតព្វកិច្ចរបស់មេធាវី ............ ៧
១.៣.៣.ចំណងគតិយុត្តរវាងមេធាវី និង កូនក្តី ............ ៧

## ជំពូកទី ២

## នីតិវិធីបណ្តឹងរដ្ឋប្បវេណី


**២.១.បណ្តឹងរដ្ឋប្បវេណី** ........ ៩

២.១.១.គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី ........ ៩

២.១.២.លក្ខខណ្ឌនៃបណ្តឹង ........ ៩

២.១.៣.ផលប្រយោជន៍នៃបណ្តឹង ........ ១០

**២.២.ប្រភេទនៃបណ្តឹង** ........ ១០

២.២.១.បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ........ ១០

២.២.១.១.បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាបច្ចុប្បន្ន ........ ១១

២.២.១.២.បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលអនាគត ........ ១១

២.២.២.បណ្តឹងទាមទារឱ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្ត ........ ១១

២.២.២.១.បណ្តឹងទាមទារឱ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តដោយសកម្ម ........ ១១

២.២.២.២.បណ្តឹងទាមទារឱ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តដោយអសកម្ម ........ ១១

២.២.៣.បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ........ ១២

**២.៣.ពាក្យបណ្តឹងរដ្ឋប្បវេណី** ........ ១២

២.៣.១.ការសរសេរពាក្យបណ្តឹង ........ ១២

២.៣.១.១.ទិដ្ឋភាពច្បាប់ ........ ១២

២.៣.១.២.ការអនុវត្ត ........ ១៨

២.៣.២.ការដាក់ពាក្យបណ្តឹង ........ ១៨

២.៣.២.១.ការពិនិត្យពាក្យបណ្តឹង ........ ១៨

២.៣.២.២.ក្រោយពេលពិនិត្យពាក្យបណ្តឹង ........ ១៩


## ជំពូកទី៣

## នីតិវិធីនៃការជម្រះក្តី


**៣.១.នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ២០

៣.១.១.គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ២០

៣.១.១.១.ការអះអាងរបស់ភាគី ........ ២០

៣.១.១.២.ការកំណត់ចំណុចវិវាទ ........ ២០

៣.១.១.៣.ការរៀបចំភស្តុតាង ........................................ ២១
៣.១.២.កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........................................ ២១
៣.១.២.១.ការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួន ........................................ ២១
៣.១.២.២.ការសាកល្បងផ្សះផ្សាក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........................................ ២២
៣.១.២.៣. ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........................................ ២៣
**៣.២.ការទាញហេតុផលផ្ទាល់មាត់** ........................................ ២៤
៣.២.១.ភាពចាំបាច់នៃការទាញហេតុផលផ្ទាល់មាត់ ........................................ ២៤
៣.២.២. សកម្មភាពក្នុងទាញហេតុផលផ្ទាល់មាត់ ........................................ ២៥
៣.២.២.១. ការថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ........................................ ២៥
៣.២.២.២. ការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួនថ្មី ........................................ ២៥
៣.២.២.៣. ការពិនិត្យភស្តុតាង ........................................ ២៥
៣.២.៣.ការបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ ........................................ ២៦

**ជំពូកទី ៤**

**របកគំហើញថ្មី សេចក្តីសន្និដ្ឋាន និង អនុសាសន៍**

**របកគំហើញថ្មី** ........................................ ២៧
**សេចក្តីសន្និដ្ឋាន** ........................................ ៣០
**អនុសាសន៍** ........................................ ៣១
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រមនីតិវិធីរដ្ឋប្បវេណី គឺត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំលើកទី៤ នីតិកាលទី៣ ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ នៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ កន្លងទៅ ហើយបានបញ្ជាក់អំពីគោលបំណងរបស់ខ្លួនថា៖ "ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីមានគោលបំណងការពារសិទ្ធិស្របច្បាប់របស់បុគ្គល"[1] តាមរយៈការដោះស្រាយវិវាទដោយបង្ខំ ហើយតុលាការមានអំណាច លើការដោះស្រាយវិវាទនេះដោយផ្អែកតាមច្បាប់ ពុំមានន័យថារដ្ឋបង្កើតប្រព័ន្ធច្បាប់ដើម្បីដាក់ទាន ឬ ផ្ដល់អំណោយជូនប្រជារាស្ត្រនោះទេ ផ្ទុយទៅវិញបុគ្គលគ្រប់រូប ដែលនៅលើផែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងប្រជាជនកម្ពុជាផង មានសិទ្ធិក្នុងការស្វែងរកការការពារសិទ្ធិរបស់ខ្លួនតាមប្រព័ន្ធតុលាការ ដោយការដាក់ពាក្យប្ដឹងទៅកាន់តុលាការ ដើម្បីការពារសិទ្ធិដែលខ្លួនមាន និងកំពុងត្រូវបានបំពាន។

## ២.បញ្ហានៃការស្រាវជ្រាវ

ដោយហេតុថា ការរៀបចំពាក្យបណ្ដឹងមួយឱ្យស្របតាមបញ្ញត្តិនៃច្បាប់ គឺមានផលលំបាកសម្រាប់ពលរដ្ឋធម្មតា ដែលមិនបានយល់ដឹងអំពីដំណើរការ និង ការរៀបចំពាក្យបណ្ដឹងមួយដែលត្រឹមត្រូវ។ ជាក់ស្ដែង ក្នុងការអនុវត្តសព្វថ្ងៃ បានទទួលរងនូវការរិះគន់ជាច្រើន ទៅលើការរៀបចំពាក្យបណ្ដឹងមួយឱ្យបានត្រឹមត្រូវ និង ស្របតាមលក្ខខណ្ឌនៃបទប្បញ្ញត្តិ ដោយហេតុថាទម្រង់ពាក្យបណ្ដឹងនីមួយៗ គឺមានភាពខុសគ្នាទៅនឹងបញ្ញត្តិនៃច្បាប់ដែលបានកំណត់។ អាស្រ័យហេតុនេះទើបមានសំណួរជាច្រើនបានដាក់ជាចម្ងល់ថា តើទម្រង់នៃពាក្យបណ្ដឹងដែលត្រឹមត្រូវតាមបទប្បញ្ញត្តិស្ថិតនៅក្នុងទម្រង់បែបណា? ហើយការរិះគន់នោះត្រឹមត្រូវដែរឬទេ? ហើយទម្រង់នៃពាក្យបណ្ដឹងដែលកំណត់ក្នុងច្បាប់ និង ការអនុវត្តជាក់ស្ដែងមានភាពខុសប្លែកគ្នាយ៉ាងណាខ្លះ? ខ្ញុំបាទ-នាងខ្ញុំនឹងដាក់ការបង្ហាញតាមរយៈប្រធានបទមួយនេះ។

## ៣.គោលបំណង និង សារៈសំខាន់នៃការស្រាវជ្រាវ

### ៣.១.គោលបំណងនៃការស្រាវជ្រាវ

គោលបំណង គឺស្វែងរកលក្ខខណ្ឌសំខាន់នៃពាក្យបណ្ដឹងក្នុងរឿងក្ដីរដ្ឋប្បវេណី មានរបៀបក្នុងការរៀបចំរបៀបសរសេរពាក្យបណ្ដឹង និង នីតិវិធីក្នុងការដើរបណ្ដឹងទៅសាលាដំបូង។

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០២០៨/០០៨, ២៤ កញ្ញា ១៩៩៣, មាត្រា១២៨។

### ៣.២.សារៈសំខាន់នៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវស្ដីពី រឿងក្ដីរដ្ឋប្បវេណីសម្រាប់សាលាដំបូងកម្ពុជា៖ ផ្ដោតទៅលើការសរសេរពាក្យបណ្ដឹង នេះបានផ្ដល់នូវពុទ្ធិដោយផ្ទាល់ដល់និស្សិត និង អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ឱ្យទទួលបានការយល់ដឹងកាន់តែច្បាស់អំពី រឿងក្ដីរដ្ឋប្បវេណីសម្រាប់សាលាដំបូង ដែលផ្ដោតសំខាន់ទៅលើបណ្ដឹង ការសរសេរ ការរៀបចំ និង នីតិវិធីក្នុងការដើរបណ្ដឹងសម្រាប់សាលាដំបូង។ ប្រធានបទមួយនេះ ក៏អាចក្លាយទៅជាផ្នែកមួយ ឬ មូលដ្ឋានមួយសម្រាប់ទ្រទ្រង់ដល់ការសិក្សាស្រាវជ្រាវបន្ថែមទៀតអំពី រឿងក្ដីរដ្ឋប្បវេណីសម្រាប់សាលាដំបូងកម្ពុជា ឱ្យកាន់តែជឿនលឿន ទូលំទូលាយក្នុងការឈ្វេងយល់អំពីរឿងក្ដីមួយនេះ និង ដើម្បីធ្វើយ៉ាងណាឱ្យវិស័យគតិយុត្ត មានភាពល្អប្រសើរជាងនេះមួយកម្រិតទៀត។

## ៤.វិធីសាស្ត្រនៃការស្រាវជ្រាវ

- ការអង្កេតទៅលើរដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី
- ការអង្កេតទៅលើច្បាប់ជាតិនានា
- ការផ្ដល់អនុសាសន៍ផ្ទាល់ពីលោកគ្រូសាស្ត្រាចារ្យដឹកនាំ ហាប់ ផល្លី
- ការផ្ដល់អនុសាសន៍ផ្ទាល់ពីលោកមេធាវី ចិត្ត សង្វារ
- ការផ្ដល់យោបល់ និងអង្កេតពីមិត្តរួមជំនាន់
- ការវិភាគលើទិន្នន័យដែលបានប្រមូលបាន
- ការវិភាគទ្រឹស្ដី និងការអនុវត្តជាក់ស្ដែង
- ការអង្កេតជាក់ស្ដែងទៅលើពាក្យបណ្ដឹង

## ៥.កម្រិតនៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវលើប្រធានបទមួយនេះ គឺកម្រិតត្រឹមការសរសេរពាក្យបណ្ដឹងលើរឿងក្ដីរដ្ឋប្បវេណីសម្រាប់សាលាដំបូង ដែលមានដូចជាសញ្ញាណនៃរឿងក្ដីរដ្ឋប្បវេណី លក្ខខណ្ឌបណ្ដឹង និង នីតិវិធីនៃបណ្ដឹង ព្រមទាំងការវិភាគលើពាក្យបណ្ដឹង។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះចែកចេញជា ៤ ជំពូក។ ជំពូកទី១ បង្ហាញអំពី សញ្ញាណនៃរឿងក្ដីរដ្ឋប្បវេណី។ ជំពូកទី២ បង្ហាញអំពី នីតិវិធីនៃបណ្ដឹងរដ្ឋប្បវេណី។ រីឯជំពូកទី៣ បង្ហាញអំពី នីតិវិធីនៃការជម្រះក្ដី។ ចំណែកជំពូកទី៤ បង្ហាញអំពី របកគំហើញថ្មីដែលចេញពីការស្រាវជ្រាវមួយនេះ។

# ជំពូកទី១
# សញ្ញាណនៃរឿងក្តីរដ្ឋប្បវេណី

## ១.១.ភាគី

### ១.១.១.អត្ថន័យនៃភាគី

ជាទូទៅ អាចចាត់ទុកថាជាភាគីបានលុះត្រាតែមានបុគ្គលចាប់ពីពីរនាក់ ឬ ច្រើននាក់ឡើងទៅទើបអាចកំណត់ពីសមាសភាពបុគ្គលនោះបាន។ ចំពោះក្នុងរឿងក្តីរដ្ឋប្បវេណី ភាគីត្រូវបានចាត់ទុកជាប្រធាននៃបណ្តឹងរដ្ឋប្បវេណី។ ភាគី គឺជាជនដែលទាមទារនូវសាលក្រម ឬ សាលដីកាក្នុងនាមរបស់ខ្លួន ដើម្បីដោះស្រាយវិវាទ ព្រមទាំងជនដែលទាមទារឱ្យចង្អុលឈ្មោះនៅក្នុងសាលក្រម ឬ សាលដីកានោះ ក្នុងនាមជាភាគីម្ខាងទៀត។[2] ក្នុងពាក្យបណ្តឹងរដ្ឋប្បវេណីភាគី ត្រូវបានចាត់ទុកថាជាចំណុចសំខាន់មួយដែលត្រូវតែសរសេរក្នុងពាក្យបណ្តឹង សមាសភាពរបស់ភាគីត្រូវបានបង្ហាញដោយការបញ្ជាក់ ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន បន្ថែមពីនេះ ភាគីត្រូវបានគេហៅថា ដើមចោទ និង ចុងចម្លើយ។[3]

### ១.១.២.ដើមចោទ

ដើមចោទ គឺជាបុគ្គលទាំងឡាយណាដែលត្រូវបានបុគ្គលផ្សេងទៀតបំពានសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន បណ្តាលឱ្យមាន ការខូចខាត និង បាត់បង់ផលប្រយោជន៍ ដែលជាបុព្វហេតុបង្កើតឱ្យមានវិវាទកើតឡើង។ ដើមចោទ ជាភាគីដែលបានដាក់ពាក្យបណ្តឹងទៅសាលាដំបូង ដើម្បីទាមទារឱ្យចេញនូវសាលក្រមមួយដែលមានកំណត់នូវ អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ កំណត់អំពីសំណងនៃការខូចខាតដែលបង្កដោយភាគីម្ខាងទៀតចំពោះការបំពានសិទ្ធិ និង ការខូចខាត ឬ បាត់បង់ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។

### ១.១.៣.ចុងចម្លើយ

ចុងចម្លើយ គឺជាបុគ្គលទាំងឡាយណាដែលត្រូវបានការប្តឹង ឬ ការទាមទារតាមផ្លូវច្បាប់ពីសំណាក់ដើមចោទ។ នៅក្នុងពាក្យបណ្តឹង ចុងចម្លើយត្រូវបានចាត់ទុកជាបុគ្គលដែលបានបង្កការបំពារបំពានទៅលើសិទ្ធិ និងបង្កការខូចខាត បាត់បង់ផលប្រយោជន៍ស្របច្បាប់ ឬ ទំនាក់ទំនងគតិយុត្តរបស់ដើមចោទ ទោះបីជាបែបនេះក្តី ក៏មិនមានន័យថាចុងចម្លើយ គឺជាបុគ្គលដែលបានបំពារបំពានទៅលើសិទ្ធិ និង បង្កការខូចខាត បាត់បង់ផលប្រយោជន៍ស្របច្បាប់របស់ដើមចោទ។

[2] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ២២។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥។

ដោយហេតុនេះហើយនៅពេលទទួលបានការកោះហៅពីសាលាដំបូង ចុងចម្លើយអាចចូលខ្លួនទៅឆ្លើយបំភ្លឺ និងដោះសារនូវរាល់ការទាមទាររបស់ដើមចោទបាន នៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង នីតិវិធីទាញហេតុផលផ្ទាល់មាត់។

## ១.២.តុលាការ

ក្នុងរឿងក្ដីរដ្ឋប្បវេណី តុលាការជាស្ថាប័នមួយដែលអាចទទួលពាក្យបណ្ដឹងដោយស្របច្បាប់ វិនិច្ឆ័យលើរឿងក្ដី ក្នុងការដោះស្រាយវិវាទ បន្ទាប់ពីទទួលបានបណ្ដឹងពីសំណាក់ដើមចោទ។ ដំណើរការនៃការដោះស្រាយវិវាទនេះ មានការចូលរួមពីសំណាក់ ចៅក្រម ក្រឡាបញ្ជី ជាអ្នកទទួលបន្ទុកលើសំណុំរឿង។ ក្នុងករណីដែលយល់ថាមានភាពចាំបាច់ ស្ថាប័នអយ្យការដែលតំណាងដោយព្រះរាជអាជ្ញាក៏អាចចូលរួមដោះស្រាយក្នុងសំណុំរឿងបានផងដែរ។[4]

### ១.២.១.សមត្ថកិច្ចតុលាការ

ដូចដែលបានដឹងហើយថា តុលាការជាអ្នកទទួលបន្ទុកក្នុងការដោះស្រាយវិវាទក្នុងរឿងក្ដីរដ្ឋប្បវេណី បន្ទាប់ពីបានទទួលបណ្ដឹងពីដើមចោទ។ ប៉ុន្តែមានសំនួរជាច្រើនបានចោទសួរថា តើតុលាការមួយណាដែលមានសិទ្ធិជម្រះក្ដីបន្ទាប់ពីទទួលបានបណ្ដឹងដើមចោទ? តើភាគីនៃវិវាទត្រូវរកតុលាការមួយណាដែលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទរបស់ខ្លួនបានដោយស្របទៅតាមការកំណត់របស់ច្បាប់?

> សិទ្ធិជម្រះក្ដី គឺជាសិទ្ធិដែលត្រូវបានប្រគល់ទាំងស្រុងទៅឱ្យតុលាការទាំងមូល ហើយតុលាការជាអង្គភាពរដ្ឋដែលអនុវត្តសិទ្ធិជម្រះក្ដីនេះ ត្រូវបានបែងចែកជា តុលាការកំពូល (មានតែមួយសម្រាប់ទូទាំងប្រទេស) សាលាឧទ្ធរណ៍ និង សាលាដំបូងហើយតុលាការមានប្រភេទដូចគ្នាមានច្រើនកន្លែង។ ការកំណត់ស្ដីពីការបែងចែកបន្ទុកក្នុងការអនុវត្តសិទ្ធិជម្រះក្ដីនៃតុលាការប្រភេទខុសគ្នា ឬ តុលាការដែលមានប្រភេទដូចគ្នា តែច្រើនកន្លែងនោះ មានន័យថាការកំណត់នូវការបែងចែកបន្ទុកនៃសិទ្ធិជម្រះក្ដីរដ្ឋប្បវេណី គេហៅថា សមត្ថកិច្ច ជំនុំជម្រះរបស់តុលាការ។ បើមើលពីតុលាការ ទំហំនៃសិទ្ធិអំណាចដែលអាចអនុវត្តសិទ្ធិជម្រះក្ដី គេហៅថា សមត្ថកិច្ច ហើយបើមើលពីករណីពិសេសណាមួយវិញ តុលាការដែលអាចចាត់ចែងរឿងក្ដីនោះ គេហៅថា "តុលាការដែលមានសមត្ថកិច្ច"។[5]

ការកំណត់នូវតុលាការដែលមានសមត្ថកិច្ចក្នុងការជម្រះក្ដី ត្រូវបានកំណត់ទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា។ សមត្ថកិច្ចទាំងនោះបានបែងចែកទៅតាមបទដ្ឋាន និង មូលហេតុផ្សេងៗពីគ្នា ហើយការបែងចែកសមត្ថកិច្ចនេះមានដូចជា សមត្ថកិច្ចតាមលំនៅឋាន សមត្ថកិច្ចតាមទីកន្លែងត្រូវអនុវត្តកាតព្វកិច្ច ឬ

[4] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦។

[5] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្ដឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ១៣។

តាមកន្លែងនៃទ្រព្យសម្បត្តិ សមត្ថកិច្ចពិសេសចំពោះរឿងក្តីលែងលះ និង បុគ្គភាព សមត្ថកិច្ចចំពោះការទាមទារច្រើនចំណុចដោយបញ្ចូលជាមួយគ្នា សមត្ថកិច្ចដែលត្រូវបានការកំណត់ដោយតុលាការថ្នាក់លើ សមត្ថកិច្ចតាមការព្រមព្រៀងរបស់ភាគី និង សមត្ថកិច្ចដែលកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ។[6]

ប្រសិនបើតុលាការបានរកឃើញថាបណ្តឹងបានដាក់មកខុសសមត្ថកិច្ច តុលាការត្រូវផ្ទេរសមត្ថកិច្ចទៅឱ្យតុលាការដែលមានសមត្ថកិច្ចចំពោះបណ្តឹងនោះ ការផ្ទេរសមត្ថកិច្ចនេះ ត្រូវធ្វើឡើងដោយដីកាសម្រេច។[7] ភាគីអាចប្តឹងជំទាស់បាន ប្រសិនបើខ្លួនមិនពេញចិត្តចំពោះដីកាសម្រេចផ្ទេរសមត្ថកិច្ចនោះ។[8] ម៉្យាងវិញទៀតប្រសិនបើតុលាការយល់ឃើញថាមានភាពចាំបាច់ក្នុងការផ្ទេរ ដើម្បីជៀសវាងការយឺតយ៉ាវនៃនីតិវិធី តុលាការក៏អាចធ្វើការផ្ទេរសមត្ថកិច្ចបានផងដែរ។[9]

### ១.២.២.តួនាទីចៅក្រមក្នុងរឿងក្តីរដ្ឋប្បវេណី

ជាគោលការណ៍ សំណុំរឿងរដ្ឋប្បវេណីក្នុងសមត្ថកិច្ចសាលាដំបូង ត្រូវទទួលបន្ទុកជម្រះក្តីដោយចៅក្រមម្នាក់ ក៏ប៉ុន្តែសំណុំរឿងមួយចំនួន គឺត្រូវជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ក្រុមប្រឹក្សានៃចៅក្រមនេះទទួលបន្ទុកជម្រះក្តីចំពោះរឿងក្តីដែលសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងមានតម្លៃមិនតិចជាង ៥ លានរៀល និង រឿងក្តីដែលច្បាប់បានកំណត់ជាពិសេស។[10]

ការជម្រះក្តីដោយចៅក្រមម្នាក់ គឺជាវិធីចាត់តាំងចៅក្រមម្នាក់ជាតុលាការក្នុងនាមអង្គភាពជម្រះក្តី ម៉្យាងវិញទៀត ការជម្រះក្តីដោយចៅក្រមតែម្នាក់ ជារបបមួយសមស្របសម្រាប់ការវិនិច្ឆ័យ និងសម្រេចក្តីឱ្យបានឆាប់រហ័សចំពោះរឿងក្តីដែលស្រួលៗ។

នៅដំណាក់កាលនៃការជំនុំជម្រះលើកទី១ ចៅក្រមត្រូវធ្វើការពិនិត្យភស្តុតាងទាំងឡាយ ដែលបានដាក់ដោយភាគីដើមចោទ និងចុងចម្លើយក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ទាញហេតុផលហើយនោះ បន្ថែមពីនេះចៅក្រមត្រូវធ្វើការថ្លឹងថ្លែង ពិចារណាឱ្យបានល្អិតល្អន់នូវសេចក្តីថ្លែងការណ៍របស់ភាគីទាំងសងខាងក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់។ តួនាទីដែលសំខាន់គឺបន្ទាប់ពីបានបិទបញ្ចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់ចៅក្រម

---

[6] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៨ មាត្រា៩ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៤ និង មាត្រា១៥។

[7] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨។

[8] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២១។

[9] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩។

[10] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៣។

ត្រូវចេញសេចក្តីវិនិច្ឆ័យ ឬ "សាលក្រមមួយជាលាយលក្ខណ៍អក្សរ"[11] ដែលកំណត់ពីទំនាក់ទំនងគតិយុត្ត និង អត្ថិភាព និង នត្ថិភាពនៃសិទ្ធិ និង កាតព្វកិច្ច។

### ១.២.៣.តួនាទីក្រឡាបញ្ជីក្នុងរឿងក្ដីរដ្ឋប្បវេណី

ក្រឡាបញ្ជី ជាមន្ត្រីរាជការក្របខណ្ឌក្រសួងយុត្តិធម៌ដែលមានតួនាទីជាជំនួយការរបស់ព្រះរាជអាជ្ញា និង ចៅក្រមនៅគ្រប់ដំណាក់កាល។ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ធ្វើកំណត់ហេតុក្នុងដំណាក់កាលនៃនីតិវិធីទាញហេតុផលផ្ទាល់មាត់។[12]

បន្ថែមពីនេះ ក្រឡាបញ្ជីជាអ្នករក្សាទុកនូវកំណត់ហេតុទាំងអស់ដែលបានធ្វើ កាលណាសំណុំរឿងបាត់ ក្រឡាបញ្ជីជាអ្នកទទួលខុសត្រូវដោយអាចប្រឈមនឹងវិន័យរដ្ឋបាលពីក្រសួងយុត្តិធម៌។ ក្រឡាបញ្ជីជាអ្នកបញ្ជាក់ ភាពត្រឹមត្រូវលើលិខិតចម្លងដោយដាក់ថា "ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម" ដើម្បីជាប្រយោជន៍សម្រាប់សំណុំ រឿងបង្ការទុក ឬ ដើម្បីប្រើប្រាស់នៅពេលបាត់លិខិតច្បាប់ដើម។ ក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ក្រឡាបញ្ជី ត្រូវពិនិត្យមើលអំពីវត្តមានរបស់ភាគីពាក់ព័ន្ធនៅពេលមុនសវនាការ អានកំណត់ហេតុនានា ដើម្បីឱ្យអ្នកចូលរួម សវនាការបានដឹងអំពីអង្គហេតុ និង កត់ត្រារាល់សំណួរចម្លើយនាពេលសវនាការរហូតដល់បញ្ចប់។

### ១.២.៤.ការចូលរួមរបស់តំណាងអយ្យការ

អយ្យការ គឺជាស្ថាប័នមួយដែលជាអ្នកទទួលបន្ទុកក្នុងការការពារនូវផលប្រយោជន៍សារធាណៈ ដែលមាន តំណាងដោយព្រះរាជអាជ្ញា។ ជាទូទៅព្រះរាជអាជ្ញាមានវត្តមាននៅក្នុងតែរឿងក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះហើយដើរ តួជាដើមបណ្តឹងព្រហ្មទណ្ឌ ប៉ុន្តែព្រះរាជអាជ្ញាក៏អាចចូលរួមក្នុងនីតិវិធីបណ្តឹងរដ្ឋប្បវេណីបានផងដែរ ក្នុងករណី ដែលយល់ឃើញថាមានភាពចំបាច់ដើម្បីការពារផលប្រយោជន៍សាធារណៈ។[13] ក្នុងករណីនេះព្រះរាជអាជ្ញាអាច ចូលរួមបញ្ចេញមតិយោបល់ចំពោះរឿងក្តី និង អាចចូលរួមក្នុងកាលបរិច្ឆេទទាញហេតុផលផ្ទាល់មាត់បាន។[14] ម្យ៉ាង ទៀតករណីដែលភាគីគឺជាអនីតិជន តុលាការអាចចាត់តាំងព្រះរាជអាជ្ញាធ្វើជាអ្នកតំណាងពិសេសបាន ប្រសិន បើគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬ មិនមានអ្នកដែលសាកសមធ្វើជាអ្នកតំណាងពិសេសបាន។

## ១.៣.មេធាវីតំណាងដោយអាណត្តិ

មេធាវី គឺជាវិជ្ជាជីវៈឯករាជ្យ និងសេរី ក្នុងវិស័យយុត្តិធម៌ ដោយមិនស្ថិតក្រោមឥទ្ធិពលនៃអំណាចណា មួយឡើយ ហើយមេធាវីអាចប្រកបវិជ្ជាជីវៈបានតែក្នុងក្របខ័ណ្ឌនៃ គណៈមេធាវីតែប៉ុណ្ណោះ។[15] ជាគោលការណ៍

[11] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២១៣។

[12] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០៩ និង មាត្រា១១៧។

[13] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦។

[14] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ០៩ មិថុនា ២០១០, មាត្រា៣០។

[15] ច្បាប់ស្តីពីស្តីពីលក្ខន្តិកៈមេធាវី, លេខ នស/រកម/០៨៩៥/០៦, ១៥ មិថុនា ១៩៩៥, មាត្រា១។

មានតែមេធាវីប៉ុណ្ណោះដែលអាចក្លាយជាអ្នកតំណាងដោយអាណត្តិបាន លើកលែងតែមានការ កំណត់ដោយច្បាប់ដទៃទៀត ឬ ក្នុងរឿងក្តីដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃតិចជាង ១ លានរៀល។ [16]

### ១.៣.១.ការទទួលបានសិទ្ធិតំណាងដោយអាណត្តិ

ភាគី នៃសំណុំរឿងក្តីរដ្ឋប្បវេណីមានសិទ្ធិស្វែងរកមេធាវី ឱ្យជួយការពារផលប្រយោជន៍របស់ខ្លួន ឬ ឱ្យធ្វើជាអ្នកតំណាងដោយអាណត្តិរបស់ខ្លួនបានគ្រប់ដំណាក់កាលនៃនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណី។ ការទទួលសិទ្ធិតំណាងដោយអាណត្តិនេះគឺបានពីការបង្ហាញឆន្ទៈរបស់ភាគី អំពីការផ្តល់សិទ្ធិតំណាងដោយអាណត្តិ តាមលិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរ។[17]

### ១.៣.២.សិទ្ធិ និង ភាតព្វកិច្ចរបស់មេធាវី

មេធាវីតំណាងដោយអាណត្តិ " អាចធ្វើរាល់សកម្មភាពបណ្តឹង ដែលចាំបាច់ក្នុងការបន្តនីតិវិធីដូចជា ការដាក់ពាក្យបណ្តឹង ការឆ្លើយដោះសារចំពោះបណ្តឹង ការប្តឹងតប ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ជាដើម ចំពោះរឿងក្តីដែលខ្លួនទទួលអាណត្តិ។"[18] ម្យ៉ាងទៀតមេធាវី អាចផ្តល់យោបល់ផ្នែកច្បាប់ រៀបចំតាក់តែងលិខិតស្នាម កិច្ចសន្យា ផ្សេងៗឱ្យកូនក្តី ឬ អ្នកដែលបានពឹងពាក់ ក្នុងវិស័យគតិយុត្ត។[19] មេធាវី ក៏អាចបំពេញតួនាទីជាអ្នកផ្សះផ្សា សម្រុះសម្រួលតាមការចាត់តាំងរបស់គូក្តី ឬ ចៅក្រមដែលកាន់រឿងក្តីបានដែរ។

មេធាវី មានកាតព្វកិច្ចខ្ពស់ក្នុងការទទួលខុសត្រូវចំពោះកូនក្តីរបស់ខ្លួន ដោយការប្រឹងប្រែងប្រើប្រាស់ចំណេះ ដឹង និង វិជ្ជាជីវៈរបស់ខ្លួន ដើម្បីការពារកូនក្តីចំពោះមុខតុលាការ បន្ថែមពីនេះមេធាវីត្រូវពន្យល់ ណែនាំពីគំនិត ផ្តល់យោបល់ ឬ ប្រាប់ពីនីតិវិធីណាមួយដើម្បីជាប្រយោជន៍ជូនកូនក្តី។

### ១.៣.៣.ចំណងគតិយុត្តរវាងមេធាវី និងកូនក្តី

មេធាវី និង កូនក្តី មានចំណងគតិយុត្តទៅវិញទៅមក ដោយសារតែកិច្ចន្យាផ្តល់សេវាកម្មផ្លូវច្បាប់ ដែលមានដូចជាលិខិតពឹងមេធាវីពីកូនក្តី ឬ លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ។ មេធាវីត្រូវបំពេញកាតព្វកិច្ច ជាអ្នកតំណាងដោយការទទួលខុសត្រូវ ចំពោះរាល់ការសម្រេចចិត្តទាំងឡាយដែលជាប្រយោជន៍របស់ កូនក្តី មេធាវីត្រូវទទួលបានការយល់ព្រមជាមុនពីកូនក្តី។ ចំពោះកូនក្តីត្រូវបំពេញកាតព្វកិច្ចបង់កម្រៃសេវាទៅមេធាវីតាមការព្រមព្រៀងរវាងខ្លួន និង មេធាវីដែលខ្លួនបានផ្តល់សិទ្ធិតំណាងដោយអាណត្តិនោះ។

---

[16] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦។

[17] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣។

[18] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ៣២។

[19] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី, លេខ នស/រកម/០៨៩៥/០៦, ១៥ មិថុនា ១៩៩៥, មាត្រា៣។

បើទោះបីជាបានជ្រើសតាំងអ្នកតំណាងដោយអាណត្តិហើយក្តី ក៏កូនក្តីអាចចូលតុលាការតែឯង ដើម្បីទាញហេតុផលផ្ទាល់មាត់ដោយខ្លួនឯងបាន។[20]

[20] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥២។

# ជំពូកទី ២
# នីតិវិធីបណ្តឹងរដ្ឋប្បវេណី

## ២.១.បណ្តឹងរដ្ឋប្បវេណី

ចំពោះវិវាទដែលកើតចេញពីទំនាក់ទំនងរវាងបុគ្គលពីរ ឬ ច្រើននាក់ហើយនៅក្នុងវិវាទនោះត្រូវបានភាគីម្ខាងលើកបណ្តឹងឡើងតាមផ្លូវតុលាការ ដើម្បីដោះស្រាយ បណ្តឹងនោះ ត្រូវបានហៅថា "បណ្តឹងរដ្ឋប្បវេណី"។ ជាគោលការណ៍បណ្តឹងរដ្ឋប្បវេណី គឺជាសកម្មភាពក្នុងការទាមទារមួយ ដែលដើមចោទបានធ្វើទៅចុងចម្លើយនៅតុលាការនៃការជំនុំជម្រះលើកទី១ ដោយលើកការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ឯកជន ហើយទាមទារឱ្យតុលាការចេញសាលក្រមជាកំណត់មួយ ដោយផ្អែកលើការអះអាងទាំងអស់ដែលបានលើកឡើង ហើយសកម្មភាពនៃបណ្តឹងត្រូវធ្វើឡើងដោយវិធីដាក់ពាក្យបណ្តឹង។

### ២.១.១.គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី

សម្រាប់បណ្តឹងរដ្ឋប្បវេណី មានគោលបំណងទាមទារឱ្យតុលាការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។[21] "បុគ្គលគ្រប់រូបមានសិទ្ធិទាមទារការជំនុំជម្រះរបស់តុលាការក្នុងការដោះស្រាយវិវាទ និងការពារសិទ្ធិរបស់ខ្លួន"[22] ពោលគឺការដោះស្រាយវិវាទមិនអនុញ្ញាតឱ្យបុគ្គលឯកជនណាមួយធ្វើការដោះស្រាយដោយខ្លួនឯង ដោយការប្រើប្រាស់កម្លាំងហិង្សា ឬ អំណាចណាមួយមកកៀបសង្កត់ និង បំពានលើបុគ្គលដទៃទៀតនោះទេ។ ដូច្នេះហើយនៅក្នុងនីតិរដ្ឋ បើសិទ្ធិដែលច្បាប់ទទួលស្គាល់ចំពោះបុគ្គលឯកជនត្រូវបានគេបំពាន ឬ ក្លាយជាកម្មវត្ថុនៃវិវាទ ការការពារដោយតុលាការត្រូវផ្តល់ទៅបុគ្គល ដោយឆ្លើយតបនឹងការទាមទាររបស់បុគ្គលឯកជននោះ មានន័យថាបុគ្គលគ្រប់រូបមានសិទ្ធិដូចគ្នាក្នុងការប្តឹងទៅតុលាការដើម្បីទាមទារការជំនុំជម្រះ ដោយការវែកញែក វិនិច្ឆ័យរកភាពត្រឹមត្រូវ និង យុត្តិធម៌ពីរដ្ឋ។ ជារួម បណ្តឹងរដ្ឋប្បវេណីមានគោលបំណងជួយសង្គ្រោះសិទ្ធិរបស់បុគ្គលដែលមាន និង កំពុងត្រូវគេបំពាន។

### ២.១.២.លក្ខខណ្ឌនៃបណ្តឹង

មុនពេលតុលាការសម្រេចចេញសាលក្រមលើបណ្តឹងមួយបាន តើបណ្តឹងនោះចាំបាច់ត្រូវមានលក្ខខណ្ឌអ្វីខ្លះ? លក្ខខណ្ឌនៃបណ្តឹង គឺជាលក្ខខណ្ឌមូលដ្ឋានមួយចំនួនដែលមានបញ្ញត្តក្នុងច្បាប់ មានន័យថាបទប្បញ្ញត្តិកំណត់អំពីលក្ខខណ្ឌមួយចំនួនក្នុងការធ្វើបណ្តឹង ហើយដែលអាចឱ្យតុលាការកំណត់ និងវិនិច្ឆ័យបានក្នុងការសម្រេចសេចក្តីរបស់ខ្លួន ឬ ការចេញសាលក្រម។

[21] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២(១)។

[22] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២(២)។

បន្ថែមពីនេះ ក៏មានលក្ខខណ្ឌនៃបណ្តឹងសំខាន់ៗមួយចំនួនទៀតដូចជា៖[23]

- ការដាក់ពាក្យបណ្តឹង និង ការបញ្ជូនពាក្យបណ្តឹងដែលមានសុពលភាព
- មានភាគី និង សមត្ថភាពភាគីត្រឹមត្រូវ
- ចុងចម្លើយស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់ព្រះរាជាណាចក្រកម្ពុជា
- តុលាការចាត់ការមានសមត្ថកិច្ចលើរឿងក្តី
- ភាគីនៃបណ្តឹងមានផលប្រយោជន៍ ឬ ភាពចាំបាច់ក្នុងការទាមទារសាលក្រមស្តីពីការទាមទារតាមផ្លូវបណ្តឹងដែលត្រូវបង្ហាញក្នុងបណ្តឹងដោយដើមចោទ។

ផ្ទុយមកវិញ តុលាការមិនអាចជំរុញនីតិវិធីក្នុងការវិនិច្ឆ័យទៅមុខបានទេ ករណីតុលាការមើលឃើញថាមានខ្វះលក្ខខណ្ឌនៃបណ្តឹងណាមួយ នោះតុលាការត្រូវតែចេញសាលក្រមលើកចោលបណ្តឹងនោះ។[24] ជារួមលក្ខខណ្ឌនៃបណ្តឹង គឺជាលក្ខខណ្ឌក្នុងការចេញសាលក្រមដែលសម្រេចអំពីអង្គសេចក្តី។

### ២.១.៣.ផលប្រយោជន៍នៃបណ្តឹង

នៅពេលមានវិវាទកើតឡើង គូវិវាទព្យាយាមរកនូវដំណោះស្រាយតាមរយៈវិធានដូចជា ការចរចា ឬ ការសម្រុះសម្រួលគ្នា ប៉ុន្តែក្នុងករណីមិនអាចសម្រេចជាមួយនឹងវិធានទាំងនោះបាន នីតិវិធីបណ្តឹងតាមផ្លូវតុលាការនឹងដំណើរការនីតិវិធីក្នុងការរកដំណោះស្រាយ និង ផ្តល់យុត្តិធម៌តាមគោលការណ៍ច្បាប់ជូនគូវិវាទ។ កាលណាមានបណ្តឹង នោះការធានាបាននូវការការពារសិទ្ធិ និង ផលប្រយោជន៍នឹងមានដល់ប្រធាននៃបណ្តឹង ពោលគឺបណ្តឹងធ្វើឡើងដើម្បីការពារផលប្រយោជន៍របស់ភាគី ក្នុងគោលបំណងដោះស្រាយវិវាទស្តីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាក់លាក់ណាមួយរបស់ភាគី។[25]

## ២.២.ប្រភេទនៃបណ្តឹង

### ២.២.១.បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក គឺជាបណ្តឹងដែលដើមចោទទាមទារឱ្យតុលាការចេញសាលក្រមក្នុងការបង្គាប់ឱ្យចុងចម្លើយផ្តល់ ឬ ប្រគល់នូវវត្ថុដែលអាចជាចលនវត្ថុ ឬ អចលនវត្ថុដែលចុងចម្លើយកំពុងកាន់កាប់។ បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនេះចែកចេញជា ២ (ពីរ) ទៀតគឺ ៖

[23] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ១២១។

[24] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ១២០។

[25] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥(១)។

**២.២.១.១.បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាបច្ចុប្បន្ន**

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាបច្ចុប្បន្ន គឺជាបណ្តឹងទាមទារឱ្យផ្តល់ ឬ ប្រគល់វត្ថុ មានជាចលនវត្ថុ ឬ អចលនវត្ថុដែលពេលកំណត់ត្រូវអនុវត្តនោះបានមកដល់ហើយ មានន័យថាពេលកំណត់ត្រូវអនុវត្តសិទ្ធិទាមទារដែលបញ្ជាក់ដោយដើមចោទនោះបានមកដល់។[26]

**២.២.១.២.បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលអនាគត**

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលអនាគត គឺជាបណ្តឹងទាមទារឱ្យផ្តល់ ឬ ប្រគល់វត្ថុ មានជាចលនវត្ថុ ឬ អចលនវត្ថុដែលពេលកំណត់ត្រូវអនុវត្តនោះមិនទាន់មកដល់នៅឡើយទេ។ ចំពោះការទាមទារនេះដែរ គឺសម្រាប់ក្នុងករណីដែលមានភាពចាំបាច់តម្រូវឱ្យទាមទារមុនកាលមកដល់។[27]

ឧទាហរណ៍: ការសងប្រាក់ដែលមានកំណត់ចំនួនច្បាស់លាស់ ការសងប្រាក់ដែលបានធ្វើឡើងជាបន្តបន្ទាប់ ឬច្រើនដងតាមពេលវេលា និង ការប្រគល់ចលនវត្ថុ ឬអចលនវត្ថុជាអាទិ៍។

**២.២.២.បណ្តឹងទាមទារឱ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្ត**

បណ្តឹងទាមទារឱ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលមាន ឬ គ្មាននៃសិទ្ធិ ផ្អែកតាមការអះអាងរបស់ដើមចោទ ដែលទាមទារតាមផ្លូវបណ្តឹង។[28] បណ្តឹង នេះចែកចេញជា ២ផ្នែកទៀតគឺ ៖

**២.២.២.១.បណ្តឹងទាមទារឱ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តដោយសកម្ម**

បណ្តឹងទាមទារឱ្យបញ្ជាក់ដោយសកម្ម គឺជាបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិដែលមានទំនាក់ទំនងគតិយុត្តជាក់ស្តែង។

**២.២.២.២.បណ្តឹងទាមទារឱ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តដោយអសកម្ម**

បណ្តឹងទាមទារឱ្យបញ្ជាកដោយអសកម្ម គឺជាបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិដែលមានទំនាក់ទំនងគតិយុត្តជាក់ស្តែង។ ឧទាហរណ៍: សិទ្ធិប្រត្យក្ស ទំហំនៃអានុភាពហ៊ីប៉ូតែក បណ្តឹងទាមទារឱ្យបញ្ជាក់ពីនត្ថិភាពនៃកាតព្វកិច្ចជាប្រាក់ដោយមានការបញ្ជាក់ពីចំនួនទឹកប្រាក់នៃកាតព្វកិច្ច បណ្តឹងទាមទារឱ្យបញ្ជាក់អំពីសិទ្ធិជួលជាដើម។

---

[26] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ៤៥។

[27] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៦។

[28] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ៤៦។

ប្រភេទនៃបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនេះ គឺច្បាប់បានហាមឃាត់រាល់ការដាក់ពាក្យបណ្តឹងដែលទាមទារឱ្យបញ្ជាក់ពីសុពលភាព ឬ មោឃភាពនៃបញ្ញត្តិច្បាប់អរូបី ឬ មោឃភាពបញ្ញត្តិនៃព្រះរាជក្រឹត្យ ឬ ព្រះរាជក្រមណាមួយ ឬ បញ្ជាក់អំពីអតីតកាល និង អនាគតកាល។

### ២.២.៣.បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងដែលប្រកាសបង្កើតសារជាថ្មីនូវទំនាក់ទំនងគតិយុត្ត ឬប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត។ ឧទាហរណ៍: បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ បណ្តឹងទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍ បណ្តឹងទាមទារលែងលះ បណ្តឹងបដិសេធបិតុភាព បណ្តឹងទាមទារកាត់កាល ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម និង ការទាមទារឱ្យបញ្ជាក់ពីមោឃភាពនៃមរតកសាសន៍។

## ២.៣.ពាក្យបណ្តឹងរដ្ឋប្បវេណី

### ២.៣.១.ការសរសេរពាក្យបណ្តឹង

#### ២.៣.១.១. និដ្ឋភាពច្បាប់

ការប្តឹងត្រូវធ្វើឡើងដោយដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរដាក់ទៅតុលាការ ហើយដើម្បីឱ្យបណ្តឹងមួយនោះមានសុពលភាព និង ត្រូវបានតុលាការចាត់ចែងតាមនីតិវិធីបាន បណ្តឹងត្រូវសរសេរបញ្ជាក់នូវចំណុច និង លក្ខខណ្ឌសំខាន់ៗ ដូចដែលមានចែងតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលកំណត់អំពីរបៀបសរសេរ និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង និង របៀបដាក់បណ្តឹង ក្នុងនោះមាន ៖

ក.ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។

នៅក្នុងពាក្យបណ្តឹង ក្រៅពីចំណុចដែលបានកំណត់នៅក្នុង ចំណុច (ខ) នៃកថាខណ្ឌទី ២ខាងលើនេះ ដើមចោទគប្បីសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងតាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង។ ពាក្យបណ្តឹងដែលមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួនត្រូវចាត់ចែងជាឯកសារត្រៀមផងដែរ។

ដើម្បីឱ្យកាន់តែច្បាស់ គឺត្រូវធ្វើការវិភាគបន្ថែមទៅលើទ្រឹស្ដីតាមចំណុចមួយៗ ៖

ក.ភាគី និង អ្នកតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងនីតិបុគ្គល

ដើម្បីឱ្យពាក្យបណ្ដឹងមានសុពលភាព ច្បាប់តម្រូវឱ្យភាគីសរសេរឈ្មោះ ភាគី និង អ្នកតំណាងដែលច្បាប់បានកំណត់។ ប្រសិនបើរូបវន្តបុគ្គលត្រូវសរសេរអំពីអាសយដ្ឋាន និង ឈ្មោះ ហើយបើនីតិបុគ្គលវិញត្រូវសរសេរ នាមករណ៍ ឬ ឈ្មោះ និង ទីតាំងនៃទីស្នាក់ការរបស់នីតិបុគ្គលនោះ (បើជាក្រុមហ៊ុន គឺទីស្នាក់ការនាយក)។ ការបញ្ញត្តិនេះ គឺដើម្បីឱ្យដឹងថា តើអ្នកណាជាដើមចោទ? អ្នកណាជាចុងចម្លើយ? គឺត្រូវបញ្ជាក់ឱ្យច្បាស់លាស់ ជៀសវាងកុំឱ្យមានការច្រឡំនឹងអ្នកផ្សេងពីព្រោះថា ពេលដែលបានដាក់ពាក្យបណ្ដឹងហើយតុលាការធ្វើការវិនិច្ឆ័យស្ដីពីវិវាទរវាងដើមចោទ និង ចុងចម្លើយនោះ ហើយអានុភាពនៃសាលក្រមដែលចេញដោយតុលាការនឹងមានឥទ្ធិពលទៅលើភាគី និងចងភាគីនោះ។[29]

ខ.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

នៅក្នុងពាក្យបណ្ដឹង ដើមចោទត្រូវបញ្ជាក់ឱ្យច្បាស់លាស់ អំពីខ្លឹមសារនៃសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមដែលខ្លួនទាមទារ។[30] ការបញ្ញត្តលើការសរសេរអំពីខ្លឹមសារនៃសាលក្រម ដែលទាមទារឱ្យតុលាការចេញគឺផ្អែកទៅលើប្រភេទនៃបណ្ដឹងដូចខាងក្រោម ៖

(១).បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក

បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក គឺជាបណ្ដឹងដែលដើមចោទអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារតាវកាលិកមួយ ដែលជាការទាមទារតាមផ្លូវបណ្ដឹង ហើយការទាមទារនេះ គឺទាមទារឱ្យតុលាការចេញសាលក្រមឱ្យចុងចម្លើយផ្ដល់តាវកាលិកកំណត់មួយដោយផ្អែកលើសិទ្ធិដែលមាននោះ។[31] គួយ៉ាងដូចជានៅក្នុងរឿងក្ដីស្ដីពីការទាមទារប្រាក់កម្ចី ការសរសេរខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ គឺ "បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១០.០០០.០០០ (ដប់លានរៀល) ឱ្យទៅដើមចោទ"។

ក្នុងគោលគំនិតច្បាប់ ក្នុងការសរសេរអំពីខ្លឹមសារនៃសាលក្រម ដែលដើមចោទសុំទាមទារឱ្យតុលាការចេញ គឺគេពុំចាំបាច់បញ្ជាក់ពីលក្ខណៈនៃទឹកប្រាក់ដែលដើមចោទទាមទារទេ មានន័យថាចំណុចដែលត្រូវបញ្ជាក់នោះគឺសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ព្រោះថាលក្ខណៈនៃទឹកប្រាក់ដូចជាប្រាក់កម្ចី ឬ ប្រាក់ថ្លៃលក់វត្ថុជាដើម នឹងត្រូវសរសេរបញ្ជាក់នៅក្នុង "អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ"។ ម្យ៉ាងវិញទៀត នៅពេល

[29] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩៨(១)។

[30] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥(២)(ខ)។

[31] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្ដឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៨), ៩៤។

ដែលមានវិវាទទាក់ទងនឹងបញ្ហាដែលពិបាកនឹងកំណត់ឱ្យបានច្បាស់លាស់អំពីលក្ខណៈនៃទឹកប្រាក់ទាមទារ គេពុំអាចកំណត់លក្ខណៈនៃទឹកប្រាក់នេះឱ្យច្បាស់លាស់បានទេ។ ហេតុនេះការមិនសរសេរពីលក្ខណៈទឹកប្រាក់ជាមានភាពងាយស្រួលជាង ប៉ុន្តែប្រសិនបើសរសេរពីលក្ខណៈទឹកប្រាក់ក៏មិនខុសដែរ។

(២).បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងដែលដើមចោទអះអាងអំពីអត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តកំណត់មួយ ដែលជាការទាមទារតាមផ្លូវបណ្តឹង ហើយការទាមទារនោះ គឺសុំឱ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មី ឬ ប្តូរ ឬ រំលត់នូវទំនាក់ទំនងគតិយុត្តដោយផ្អែកលើសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនោះ។[32] តួយ៉ាងដូចជានៅក្នុងរឿងក្តីលែងលះ ចំពោះការសរសេរខ្លឹមសារនៃសាលក្រមដែលដើមចោទ សុំទាមទារឱ្យតុលាការចេញ គឺ "ឱ្យដើមចោទ និង ចុងចម្លើយលែងលះពីគ្នា ចាប់ពីពេលសាលក្រមចូលជាស្ថាពរ"។

ក្នុងគោលគំនិតច្បាប់ នៅក្នុងពាក្យបណ្តឹង ដើមចោទត្រូវសរសេរបញ្ជាក់ឱ្យច្បាស់អំពីមូលហេតុនៃការលែងលះ ប៉ុន្តែនៅក្នុងផ្នែកខ្លឹមសារនៃសាលក្រមដែលដើមចោទសុំទាមទារឱ្យតុលាការចេញ ដើមចោទមិនត្រូវសរសេរអំពីមូលហេតុនៃការលែងលះទេ ព្រោះថាដើមចោទនឹងសរសេរអំពីមូលហេតុនៃការលែងលះនៅក្នុងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ។

(៣).បណ្តឹងទាមទារឱ្យបញ្ជាក់

បណ្តឹងទាមទារឱ្យបញ្ជាក់ គឺជាបណ្តឹងដែលដើមចោទអះអាងនូវអត្ថិភាព ឬ នត្ថិភាពសិទ្ធិ ឬទំនាក់ទំនងគតិយុត្តកំណត់មួយ ដែលទាមទារឱ្យតុលាការចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិឬទំនាក់ទំនងគតិយុត្តនោះ។[33] តួយ៉ាងដូចជានៅក្នុងរឿងក្តីអំពីការទាមទារឱ្យបញ្ជាក់ពីកម្មសិទ្ធិលើផ្ទះ ការសរសេរ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ គឺ "ទាមទារឱ្យបញ្ជាក់ថា ដើមចោទមានកម្មសិទ្ធិនៅលើផ្ទះទំហំ ៧០ ម៉ែត្រការ៉េ ដែលជាផ្ទះលេខ ០៥ ស្ថិតនៅផ្លូវលេខ២០៥ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ"។

គ.អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ

អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺជាអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារតាមផ្លូវបណ្តឹង។[34] មូលហេតុ ដែលចាំបាច់ត្រូវសរសេរអំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារក្នុងពាក្យបណ្តឹង

[32] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ៤៩។

[33] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ៤៦។

[34] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥(៣)។

គឺដើម្បីកុំឱ្យមានការភាន់ច្រឡំ ឬ មានការបែងចែកមិនច្បាស់លាស់នូវការទាមទារ ដែលជាកម្មវត្ថុនៃការជំនុំជម្រះ និងការសម្រេចសេចក្តីទៅនឹងការទាមទារផ្សេងទៀត។[35] ដូច្នេះច្បាប់បញ្ញត្តិឱ្យសរសេរអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺសំដៅទៅលើអង្គហេតុដែលអាចធ្វើការសំគាល់កុំឱ្យមានការភាន់ច្រឡំរវាងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តអះអាងដោយដើមចោទ និង សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដទៃទៀត។ ការសរសេរអំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺខុសគ្នាទៅតាមប្រភេទនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនីមួយៗដូចខាងក្រោម[36]៖

(១).សិទ្ធិអះអាងដោយដើមចោទជាសិទ្ធិប្រត្យក្ស

ក្នុងករណីដែលសិទ្ធិអះអាងដោយដើមចោទជាសិទ្ធិប្រត្យក្ស ដែលជាសិទ្ធិផ្តាច់មុខ មានន័យថា សិទ្ធិនោះមិនអាចមានអត្ថិភាពជាន់គ្នាលើកម្មវត្ថុតែមួយបានឡើយ (ករណីលើកលែងតែសិទ្ធិប្រាតិភោគប្រត្យក្សប៉ុណ្ណោះ) (ឧទាហរណ៍: មិនអាចមានកម្មសិទ្ធិពីរលើដីតែមួយបានទេ)។ ហេតុនេះដើម្បីធ្វើការបញ្ជាក់នូវសិទ្ធិគ្រាន់តែសរសេរអំពីប្រធាននៃសិទ្ធិ (ឧទាហរណ៍ដើមចោទ) កម្មវត្ថុនៃសិទ្ធិ (ឧទាហរណ៍ ដីធ្លីកន្លែងណាមួយ) ព្រមទាំងប្រភេទ និងខ្លឹមសារនៃសិទ្ធិ (ឧទាហរណ៍ កម្មសិទ្ធិ, សិទ្ធិជួលអចិន្ត្រៃយ៍, ផលុបភោគ, សិទ្ធិប្រើប្រាស់, សិទ្ធិអាស្រ័យនៅ គឺជាការគ្រប់គ្រាន់) ។

(២).សិទ្ធិអះអាងដោយដើមចោទជាសិទ្ធិលើបំណុល

ក្នុងករណីដែលសិទ្ធិអះអាងដោយដើមចោទជាសិទ្ធិលើបំណុល ដើមចោទអាចមានសិទ្ធិច្រើនចំពោះចុងចម្លើយ ដោយមានមូលហេតុនៃការបង្កើតសិទ្ធិនោះផ្សេងគ្នា។ ហេតុនេះដើម្បីធ្វើការបញ្ជាក់នូវសិទ្ធិនោះ ដើមចោទត្រូវសរសេរនៅក្នុងពាក្យបណ្តឹងអំពីប្រធាននៃសិទ្ធិ កម្មវត្ថុនៃសិទ្ធិ ប្រភេទ និងខ្លឹមសារនៃសិទ្ធិ ព្រមជាមួយនឹងមូលហេតុនៃការបង្កើតសិទ្ធិនោះ។

ឧទាហរណ៍ រវាងភាគីដូចគ្នា សិទ្ធិទាមទារឱ្យបង់ប្រាក់ ៨០០០ដុល្លារ អាចមានអត្ថិភាព ដោយសារជាសិទ្ធិទាមទារឱ្យសងប្រាក់កម្ចី ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើងនៅថ្ងៃទី០១-០៦-២០០៤ ឬ ជាសិទ្ធិទាមទារប្រាក់ថ្លៃលក់ ដោយផ្អែកលើកិច្ចសន្យាលក់ទិញដែលបានបង្កើតឡើងនាពេលវេលាផ្សេងទៀត ឬ ជាសិទ្ធិទាមទារសំណងនៃការខូចខាតដោយសារគ្រោះថ្នាក់ចរាចរណ៍ជាដើម។ ហេតុនេះ ដើម្បីធ្វើការបញ្ជាក់សិទ្ធិ ក្រៅពីការសរសេរអំពីប្រធាននៃសិទ្ធិ (ឧទាហរណ៍ដើមចោទ) កម្មវត្ថុនៃសិទ្ធិ (ឧទាហរណ៍ចុងចម្លើយ) ប្រភេទ និង ខ្លឹមសារនៃសិទ្ធិ(ឧទាហរណ៍ សិទ្ធិទាមទារឱ្យបង់ប្រាក់៨០០០ដុល្លារ) ត្រូវសរសេរអំពីមូលហេតុនៃ

[35] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ៥៤។

[36] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ៥៤។

កំណើតនៃសិទ្ធិនោះ (ឧទាហរណ៍ កិច្ចសន្យាខ្ចីបរិភោគ កិច្ចសន្យាលក់ទិញ គ្រោះថ្នាក់ចរាចរណ៍ ដែលកើតឡើងនៅកាលបរិច្ឆេទណាមួយ)។

នៅក្នុងករណីនៃសំណុំរឿងគំរូ រៀបចំដោយសាលាភូមិន្ទចៅក្រមនិងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA បានសរសេរសេរសេរអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារគឺ ៖

ក.ការទាមទារអោយសងប្រាក់កម្ចីចំនួន ៨០០០ ដុល្លារ ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ដែលបានបង្កើតឡើងរវាងដើមចោទ និងចុងចម្លើយនៅថ្ងៃទី ០១-០៦-២០០៤

ខ.ការទាមទារការប្រាក់ចំនួន ២ឆ្នាំគឺ ១៦០០ដុល្លារ ដែលជាការគណនាតាមអត្រាការប្រាក់ ១០% ក្នុង ១ឆ្នាំដែលបានសន្យាពេលបង្កើតកិច្ចសន្យាខាងលើ។

គ.ការទាមទារការប្រាក់នៃការយឺតយ៉ាវ ២០% ក្នុង១ឆ្នាំ ដោយគណនាពីថ្ងៃទី ០២-០៦-២០០៦ ដែលជាថ្ងៃបន្ទាប់នៃកាលកំណត់ដែលបានសន្យា ពេលបង្កើតកិច្ចសន្យាខាងលើរហូតដល់ថ្ងៃដែលបានសងចប់សព្វគ្រប់។

ក្នុងចំណោមការទាមទារទាំង ៣ ចំណុចខាងលើ យើងឃើញថា ការទាមទារក្នុងចំណុច (ខ) និងចំណុច (គ) គឺផ្សេងពីការទាមទារក្នុងចំណុច (ក) ហេតុនេះដើម្បីធ្វើការបែងចែកការទាមទារឱ្យបានច្បាស់ ដើមចោទ គប្បីលើកឡើងនូវអង្គហេតុបញ្ជាក់នូវការទាមទារនីមួយៗនៅក្នុងពាក្យបណ្តឹងរបស់ខ្លួន។

លើសពីនេះ ពេលគណនានៃតម្លៃកម្មវត្ថុបណ្តឹង មានតែតម្លៃនៃកម្មវត្ថុបណ្តឹងនៃចំណុច (ក) ប៉ុណ្ណោះដែលត្រូវ យកមកធ្វើជាមូលដ្ឋាននៃការគណនាពន្ធដាក់ពាក្យបណ្តឹង ចំណែកឯតម្លៃនៃកម្មវត្ថុបណ្តឹងនៅចំណុច (ខ) និង (គ) ដែលជាការទាមទារបន្ទាប់បន្សំ មិនត្រូវយកមកធ្វើជាមូលដ្ឋាននៃការគណនាទេ។

យោងតាមបញ្ញត្តិនៃមាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ និងកថាខណ្ឌទី ៣, ដើម្បីឱ្យកាន់តែច្បាស់ នៅក្នុងពាក្យបណ្តឹងរវាង "អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ" និង "អង្គហេតុដែលជាមូលហេតុនៃការទាមទារ" គប្បីសរសេរដាច់ដោយឡែកពីគ្នា។

ឃ.អង្គហេតុដែលជាមូលហេតុនៃការទាមទារ

សម្រាប់អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលបង្កើតនូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាសិទ្ធិទាមទារតាមផ្លូវបណ្តឹង មានន័យថា នៅក្នុងពាក្យបណ្តឹង គឺត្រូវបង្ហាញអំពីកាកើតមានឡើងនៃការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ។

ឧទាហរណ៍ ក្នុងករណីនៃសំណុំរឿងគំរូ រៀបចំដោយសាលាភូមិន្ទចៅក្រម និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA គឺដើមចោទបានសរសេរអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារនៅក្នុងពាក្យបណ្តឹង។ ការទាមទារឱ្យសងប្រាក់កម្ចីចំនួន ៨០០០ ដុល្លារ ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ

ដែលបានបង្កើតឡើងរវាងដើមចោទ និង ចុងចម្លើយនៅថ្ងៃទី ០១-០៦-២០០៤។ ចំណែកឯអង្គហេតុដែលជាមូលហេតុនៃការទាមទារ មានបន្ថែមចំនួន២ទៀត គឺដើមចោទបានប្រគល់ប្រាក់ចំនួន ៨០០០ដុល្លារ ឱ្យចុងចម្លើយ ហើយកាលកំណត់សង គឺថ្ងៃទី ០១-០៦-២០០៦ ក៏បានកន្លងផុតទៅហើយដែរ។

ង.អង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារនិងភស្តុតាង

តាមគោលការណ៍ច្បាប់ តម្រូវឱ្យដើមចោទសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវ "អង្គហេតុដែលជាមូលហេតុនៃការទាមទារ" "អង្គហេតុសំខាន់ៗដែលពាក់ព័ន្ធ" និង "ភស្តុតាង" "អង្គហេតុសំខាន់ៗដែលពាក់ព័ន្ធ" មានដូចជា "អង្គហេតុប្រយោល"។[37]

អង្គហេតុប្រយោល គឺជាអង្គហេតុទាំងឡាយដែលអាចធ្វើឱ្យគេសន្និដ្ឋានអំពីអត្ថិភាព ឬ នត្ថិភាព នៃអង្គហេតុចម្បងបាន (អង្គហេតុផ្ទាល់)។[38]

អង្គហេតុចម្បង គឺជាអង្គហេតុដែលនាំឱ្យមានអានុភាពតាមផ្លូវច្បាប់ មានន័យថាជាអង្គហេតុដែលបង្កើត ឬ ជាឧបសគ្គនៃការកកើត ឬ ការរារាំង ឬ ការរំលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត។[39] ឧទាហរណ៍ អង្គហេតុ "លោក **ក** បានឱ្យលោក **ខ** ខ្ចីប្រាក់ចំនួន ៥០០០ដុល្លារ " នេះជាអង្គហេតុដែលបង្កើតសិទ្ធិ។ អង្គហេតុ "កិច្ចសន្យាកើតឡើងដោយមានវិការៈនៃការបង្ហាញឆន្ទៈ" នេះជាអង្គហេតុដែលជាឧបសគ្គនៃការកកើតសិទ្ធិ។ អង្គហេតុ "ចុងចម្លើយបានបង់ប្រាក់ឱ្យដើមចោទចំនួន ៥០០០ដុល្លារ រួចហើយ" នេះជាអង្គហេតុដែលរំលត់សិទ្ធិ។ អង្គហេតុ "កាលកំណត់សងមិនទាន់មកដល់" នេះជាអង្គហេតុដែលរារាំងការអនុវត្តសិទ្ធិ។

ក្រៅឡែកមកវិញ ចំពោះអង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលបង្កើតសិទ្ធិតាមផ្លូវបណ្ដឹង ហើយជាអង្គហេតុចម្បងដែលដើមចោទបានអះអាងដំបូងបំផុត។ ចំណែកអង្គហេតុចម្បង គឺជាទស្សនៈទូលំទូលាយជាង "អង្គហេតុដែលជាមូលហេតុនៃការទាមទារ" ដោយសារតែមានរួមទាំង "អង្គហេតុតវ៉ា" ដែលអះអាងដោយចុងចម្លើយ ឬ "អង្គហេតុតវ៉ាតប" ដែលអះអាងដោយដើមចោទផងដែរ។

ដើម្បីឱ្យកាន់តែច្បាស់ សូមមើលទម្រង់ពាក្យបណ្ដឹងសម្រាប់សាលាដំបូងខេត្ត/ក្រុងដែលស្របតាមលក្ខខណ្ឌច្បាប់ដែលមានក្នុងឧបសម្ព័ន្ធទី១។ ថែមទាំងរូបមន្តនៃពាក្យបណ្ដឹងសម្រាប់សាលាដំបូង ដែលរៀបចំ

---

37 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥(៣)។

38 Prof. Mori Tomoya, "មូលដ្ឋានគ្រឹះនៃការទទួលស្គាល់អង្គហេតុ," (ឯកសារជា Power Point សម្រាប់ការបណ្ដុះបណ្ដាលដើម្បីជួយក្នុងការផ្សព្វផ្សាយក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា លើកទី៣, ឆ្នាំ ២០១៤), ៧។

39 Prof. Mori Tomoya, "មូលដ្ឋានគ្រឹះនៃការទទួលស្គាល់អង្គហេតុ," (ឯកសារជា Power Point សម្រាប់ការបណ្ដុះបណ្ដាលដើម្បីជួយក្នុងការផ្សព្វផ្សាយក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា លើកទី៣, ឆ្នាំ ២០១៤), ៧។

ដោយសាលាភូមិន្ទចៅក្រម និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន JICA ដែលមាននៅក្នុងឧបសម្ព័ន្ធ២។

**២.៣.១.២.ការអនុវត្ត**

ជាគោលការណ៍ បណ្តឹងមួយដែលសមស្របតាមច្បាប់ ហើយតុលាការទទួលយកបណ្តឹងនោះបាន លុះត្រាតែបណ្តឹងនោះបានបំពេញគ្រប់លក្ខខណ្ឌនៃបណ្តឹងបានត្រឹមត្រូវ និងពេញលេញតាមគោលការណ៍ច្បាប់។ ក្នុងករណីដែលបណ្តឹងមួយមានលក្ខណៈផ្ទុយនឹងគោលការណ៍ច្បាប់ ឬ មានភាពខ្វះចន្លោះណាមួយ នោះតុលាការនឹងចេញសាលក្រមលើកបណ្តឹងនោះចោលតែម្តង។[40]

តាមទិដ្ឋភាព និង ការអនុវត្តលើពាក្យបណ្តឹងជាក់ស្តែង ដែលមានទម្រង់នៅក្នុងឧបសម្ព័ន្ធទី៣ គឺមានភាពខ្វះចន្លោះ ខុសពីទម្រង់ពាក្យបណ្តឹងតាមបញ្ញត្តិមាត្រា ៧៥ ក្រមរដ្ឋប្បវេណីដែលមានទម្រង់ដូចនៅក្នុងឧបសម្ព័ន្ធទី១។

**២.៣.២.ការដាក់ពាក្យបណ្តឹង**

ចំពោះការដាក់ពាក្យបណ្តឹង ភាគី ឬ អ្នកតំណាងភាគីត្រូវដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ទៅសាលាដំបូង។[41] ករណីលើកលែង គឺមានបញ្ញត្ត មួយដែលច្បាប់អនុញ្ញាតឱ្យធ្វើបណ្តឹងដោយផ្ទាល់មាត់បាន (ឧទាហរណ៍ ពាក្យបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិច ដែលជារឿងក្តីមួយដែលច្បាប់អនុញ្ញាតឱ្យធ្វើបណ្តឹងដោយផ្ទាល់មាត់បាន[42])។

**២.៣.២.១.ការពិនិត្យពាក្យបណ្តឹង**

ការពិនិត្យពាក្យបណ្តឹង គឺជាការពិនិត្យភាពស្រប ឬ មិនស្របលក្ខខណ្ឌនៃពាក្យបណ្តឹង ពោលគឺតុលាការត្រូវពិនិត្យ និង ឱ្យប្រាកដថាពាក្យបណ្តឹងនោះមានសរសេរគ្រប់ចំណុចសំខាន់ដែលចាំបាច់ក្នុងការសរសេរពាក្យបណ្តឹងឬទេ?[43] ព្រមទាំងការបង់ពន្ធសម្រាប់ការដាក់ពាក្យបណ្តឹងរបស់ដើមចោទនោះឬនៅ?[44] ករណីឃើញថាពាក្យបណ្តឹងនោះមានចំណុចខ្វះខាតលើចំណុចសំខាន់ណាមួយ នោះនីតិវិធីរបស់តុលាការមិនអាចដំរុញបន្តទៅមុខបានទេ តុលាការនឹងធ្វើការបញ្ជូនត្រឡប់ពាក្យបណ្តឹងនោះវិញ ដើម្បីកែតម្រូវក្នុងអំឡុងពេលសមរម្យដែលកំណត់ដោយតុលាការ។[45]

---

[40] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៨១។

[41] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥(១)។

[42] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២២៥។

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥(២)។

[44] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦១(១)។

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៨។

ដោយឡែក រាល់ការគណនាតម្លៃនៃកម្មវត្ថុ គឺត្រូវធ្វើឡើងដោយផ្អែកលើសេចក្ដីបញ្ជាក់ដំបូង ហើយសេចក្ដីបញ្ជាក់ដំបូងអាចធ្វើឡើងដោយការបង្ហាញបង្កាន់ដៃ ឬ ឯកសារកិច្ចសន្យា ជាអាទិ៍។ នៅក្នុងករណីដែលពុំអាចរកឯកសារទាំងនោះបានទេ តម្លៃនៃកម្មវត្ថុនឹងត្រូវកំណត់ទៅតាមសេចក្ដីបញ្ជាក់ដំបូងរបស់ដើមចោទ។[46] ចំពោះវិធីគណនាប្រាក់ពន្ធដែលត្រូវបង់ គឺត្រូវផ្អែកទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹង និង ប្រភេទនៃបណ្ដឹងដែលអនុលោមទៅតាមបញ្ញត្តិនៃមាត្រា ៦១ ក្រមនីតិវិធីរដ្ឋប្បវេណី ជាមួយនឹងបទដ្ឋានគតិយុត្ត និង ប្រកាសរបស់ក្រសួងយុត្តិធម៌ផងដែរ។

**២.៣.២.២.ក្រោយពេលពិនិត្យពាក្យបណ្ដឹង**

តុលាការនឹងធ្វើការជំរុញនីតិវិធីបន្តទៅមុខទៀត បន្ទាប់ពីធ្វើការពិនិត្យពាក្យបណ្ដឹងរួចមក រួមទាំងការបង់ពន្ធរួចហើយ នោះតុលាការត្រូវបញ្ជូនពាក្យបណ្ដឹងនោះទៅគូភាគី និង កំណត់កាលបរិច្ឆេទសម្រាប់នីតិវិធីត្រៀមទាញហេតុផលលើកដំបូងយ៉ាងឆាប់រហ័សក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្ដឹងបានដាក់ទៅតុលាការ។[47]

[46] ប្រកាសស្ដីពីការកែសម្រួលឧបសម្ព័ន្ធ១ និង ឧបសម្ព័ន្ធ ៤ នៃប្រកាសលេខ ២៨ កយ ប្រក,០៧ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្ដីពី ប្រភេទពាក្យសុំដែលតម្រូវឱ្យបង់ពន្ធ ចំនួនទឹកប្រាក់នៃប្រាក់ពន្ធដាក់ពាក្យសុំ និង ចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាព ក្រៅពីពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្ដី និង មាត្រាដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ និង តម្លៃកម្មវត្ថុនៃបណ្ដឹង, លេខ ៥៤ កយប្រក/០៩, ២២ មិថុនា ២០០៩, ឧបសម្ព័ន្ធ ៤ ថ្មី។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៨០។

# ជំពូកទី៣
# នីតិវិធីនៃការជម្រះក្តី

## ៣.១.នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

បន្ទាប់ពីទទួលបាននូវពាក្យបណ្តឹងពីដើមចោទនៃរឿងក្តីរដ្ឋប្បវេណី តុលាការត្រូវធ្វើការជម្រះក្តីលើពាក្យបណ្តឹងនោះ និង ត្រូវចេញនូវសាលក្រមមួយដែលមានភាពត្រឹមត្រូវ យុត្តិធម៌ និង ជាទីពេញចិត្តចំពោះភាគីទាំងសងខាងដែលជាប្រធាននៃបណ្តឹង ដែលការជម្រះក្តីនេះត្រូវឆ្លងកាត់នូវនីតិវិធីទាញហេតុផលផ្ទាល់មាត់។ ដើម្បីធានាឱ្យបាននូវការជម្រះក្តីតាមរយៈការទាញហេតុផលផ្ទាល់មាត់ ដែលឈានទៅដល់ការទទួលបានសាលក្រមមួយ ដែលបញ្ជាក់ពីភាពត្រឹមត្រូវ និងពិតប្រាកដមួយ គឺចាំបាច់ណាស់ដែលតុលាការត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

### ៣.១.១.គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានគោលបំណងដើម្បីរៀបចំនូវសេចក្តីអះអាងរបស់ភាគី ការកំណត់នូវចំណុចវិវាទនៃរឿងក្តីដែលភាគីមិនស្របគ្នា និង ធ្វើការរៀបចំភស្តុតាងពាក់ព័ន្ធនៃរឿងក្តី។[48]

#### ៣.១.១.១.ការអះអាងរបស់ភាគី

ការអះអាង គឺជា "សេចក្តីថ្លែងការណ៍ដែលមិនមែនជាការឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍របស់ភាគីម្ខាងទៀត ហើយដែលរៀបរាប់អំពីអង្គហេតុឯករាជ្យ ឬ មតិយោបល់តាមផ្លូវច្បាប់"។[49] ក្នុងការអះអាងភាគីនឹងធ្វើការលើកឡើងនូវអង្គហេតុទាំងអស់ទោះបីជាអង្គហេតុនោះមានប្រយោជន៍ ឬ គ្មានប្រយោជន៍ចំពោះរឿងក្តី បន្ទាប់ពីឆ្លងកាត់ការអះអាងនេះហើយ តុលាការត្រូវរៀបចំការអះអាងរបស់ភាគីដោយរៀបចំនូវចំណុចដែលភាគីមានទំនាស់ ភាគីដែលមិនស្របគ្នា និងឱ្យភាគីដកការអះអាងពីអង្គហេតុដែលមិនមានប្រយោជន៍ និងលុបចោលនូវអង្គហេតុដែលភាគីបានធ្វើការអះអាងដូចគ្នាដែលជាអង្គហេតុមិនមានវិវាទ។

#### ៣.១.១.២.ការកំណត់ចំណុចវិវាទ

ការកំណត់នូវចំណុចវិវាទ អាចធ្វើឡើងបានបន្ទាប់ពីភាគីបានធ្វើការអះអាងអំពីអង្គហេតុ។ ចំណុចវិវាទគឺជាចំណុចទាំងឡាយណាដែល ភាគីទាំងសងខាងប្រកែកគ្នា ឬ មិនស្របគ្នា ក្នុងករណីដែរភាគីម្ខាងបានលើកឡើងនូវការអះអាងដែលជាអត្ថិភាពនៃអង្គហេតុណាមួយ ហើយភាគីម្ខាងទៀតបានធ្វើសេចក្តីថ្លែងការណ៍អំពីការមិនបានដឹង គឺ "ត្រូវបានសន្មតថាបានតវ៉ាចំពោះអង្គហេតុនោះ"[50] ហេតុនេះអង្គហេតុដែលភាគីបានតវ៉ា

---

[48] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០៣។

[49] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ៨០។

[50] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៩៦។

ថាមិនបាននោះនឹងត្រូវក្លាយជា ចំណុចវិវាទ។ ចំណុចវិវាទពិតប្រាកដត្រូវតែទទួលស្គាល់ដោយភាគីទាំងសងខាង និង តុលាការ។

### ៣.១.១.៣.ការរៀបចំភស្តុតាង

ការរៀបចំភស្តុតាង គឺជាការប្រមូលផ្តុំនូវភស្តុតាង ដែលពាក់ព័ន្ធនឹងរឿងក្តី ការអះអាងរបស់ភាគី ឬពាក់ព័ន្ធនឹងចំណុចវិវាទដែលត្រូវបំភ្លឺ ដែលជាមូលដ្ឋានក្នុងការវិនិច្ឆ័យនៅពេលទាញហេតុផលផ្ទាល់មាត់។ ការរៀបចំភស្តុតាង មិនមែនជានីតិវិធីពិនិត្យភស្តុតាងនោះទេ គឺតុលាការគ្រាន់តែស្តាប់ពីការអះអាងរបស់ភាគី និងកំណត់ពីចំណុចវិវាទ ដែលភាគីនៃរឿងក្តីមិនស្របគ្នា ហើយរៀបចំភស្តុតាងដែលពាក់ព័ន្ធនិងការអះអាងនោះ។[51]

### ៣.១.២.កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាភារកិច្ចរបស់តុលាការដែលត្រូវកំណត់ ជាគោលការណ៍តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។[52] នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវធ្វើឡើងនៅកាលបរិច្ឆេទមួយដែលប្រាកដ ថាភាគីទាំងសងខាងអាចចូលរួម ឬ មានវត្តមានបាន ដោយគោរពតាមគោលការណ៍ចំពោះមុខ។ បានន័យថានីតិវិធីនេះត្រូវតែធានាឱ្យបាននូវគោលការណ៍ចំពោះមុខនេះ។

ខុសពីនីតិវិធីទាញហេតុផលផ្ទាល់មាត់ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនតម្រូវឱ្យធ្វើនៅសវនាការនោះទេ គឺអាចធ្វើទៅបាននៅបន្ទប់ធម្មតាមួយ ឬ បន្ទប់របស់ចៅក្រមដែលទទួលបន្ទុករឿងក្តី ដែលអាចហៅបានថាជា "បន្ទប់ត្រៀម"[53]។ ប៉ុន្តែការដំណើរការនៃនីតិវិធី ទោះបីជាត្រូវប្រព្រឹត្តទៅនៅក្នុងបន្ទប់ត្រៀម ក៏អាចឱ្យអ្នកផ្សេងចូលស្តាប់បានផងដែរ ការអនុញ្ញាតនេះ គឺជាការសម្រេចដោយឆន្ទានុសិទ្ធិរបស់តុលាការ។

### ៣.១.២.១.ការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួន

មធ្យោបាយតទល់ គឺជាសេចក្តីថ្លែងការណ៍ ឬ ឯកសារទាំងឡាយណាដែលបានដាក់ជូនទៅតុលាការ ដើម្បីបញ្ជាក់អំពីមូលហេតុនៃការទាមទាររបស់ខ្លួន ដែលមធ្យោបាយតទល់នេះត្រូវបានធ្វើឡើងដោយដើមចោទ រីឯការធ្វើសេចក្តីថ្លែងការណ៍ ឬ ឯកសារដែលបានដាក់ជូនទៅតុលាការដើម្បីបញ្ជាក់ថា ការទាមទាររបស់ដើមចោទពុំមានមូលហេតុត្រឹមត្រូវ ដែលបានពីចុងចម្លើយគឺជា មធ្យោបាយការពារខ្លួន។ យើងអាចសំគាល់

---

[51] អ៊ុំ ប៉ូលី, "នីតិវិធីរដ្ឋប្បវេណី," (ឯកសារជា PDF សម្រាប់បង្រៀននៅ សាកលវិទ្យាល័យ បញ្ញាសាស្ត្រ,២០១០), ២៥។

[52] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៨០។

[53] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, រៀបរៀង, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៧), ១០៣។

បានថា "ទាំងមធ្យោបាយតទល់ និង មធ្យោបាយការពារខ្លួន គឺដើមចោទ និង ចុងចម្លើយអាចដាក់ទៅបានដូចគ្នា"។[54]

ការដាក់មធ្យោបាយតទល់ និង មធ្យោបាយការពារខ្លួន ត្រូវដាក់ជូនទៅតុលាការនៅពេលវេលាដែលសមរម្យមួយទៅតាមដំណើរការនៃបណ្តឹង។[55] ការប្រើប្រាស់ "គោលការណ៍ដាក់តាមកាលៈទេសៈសមរម្យ" នេះបានបង្កើតជាចម្ងល់មួយដែលចោទសួរថា តើពេលវេលាណាជាពេលវេលាសមរម្យទៅតាមដំណើរការនៃបណ្តឹង? ឆ្លើយតបលើសំណួរនេះយើងនឹងសិក្សាទៅលើច្បាប់របស់បារាំង និង ច្បាប់របស់ជប៉ុន។

យោងតាមមាត្រា ៧២ និង មាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ប្រទេសបារាំងបានអនុញ្ញាតឱ្យភាគីចុងចម្លើយអាចដាក់នូវមធ្យោបាយការពារខ្លួនបានគ្រប់ពេលវេលាទាំងអស់ ប៉ុន្តែត្រូវធ្វើឡើងមុនពេលដែលតុលាការបញ្ចប់ការវិនិច្ឆ័យលើរឿងក្តី។[56] ការដែលចុងចម្លើយអាចដាក់មធ្យោបាយការពារខ្លួនបានគ្រប់ពេលវេលានេះយើងអាចហៅជាគោលការណ៍ដាក់ពេលណាក៏បាន។

បើមើលទៅលើក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន បានជ្រើសយកគោលការណ៍ទៅតាមពេលវេលាសមរម្យនេះផងដែរ យោងតាមមាត្រា១៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន "មធ្យោបាយនៃការតទល់ និង មធ្យោបាយការពារខ្លួន អាចធ្វើឡើងនៅពេលវេលាអនុញ្ញាតដែលសមរម្យជាមួយនឹងដំណើរការនៃរឿងក្តី [បកប្រែ]។"[57] យើងអាចសង្កេតឃើញថា ក្រមនីតិវិធីរដ្ឋប្បវេណីរបស់កម្ពុជា និង ក្រមរដ្ឋប្បវេណីជប៉ុន គឺបានជ្រើសរើសយកគោលការណ៍តាមកាលៈទេសៈសមរម្យដូចគ្នា ការកំណត់យកគោលការណ៍បានរក្សានូវភាពសុចរិតរបស់ភាគីក្នុងការធ្វើបណ្តឹង បញ្ចៀសការយឺតយ៉ាវនៃនីតិវិធី មិនធ្វើឱ្យមានឧបសគ្គដល់ការការពារខ្លួនរបស់ភាគីម្ខាងទៀត ដែលខុសពីក្រមនីតិវិធីរដ្ឋប្បវេណីបារាំង បានកំណត់យកគោលការណ៍ដាក់ពេលណាក៏បានដែលអាចបង្កឱ្យមានភាពយឺតយ៉ាវនៃនីតិវិធីជម្រះក្តី ឬ មិនអាចរក្សាបាននូវភាពសុចរិតរបស់ភាគីក្នុងការធ្វើបណ្តឹង។[58]

### ៣.១.២.២.ការសាកល្បងផ្សះផ្សាក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ការផ្សះផ្សា គឺជាសកម្មភាពមួយដែលអាចធ្វើឡើងបានគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការរឿងក្តី។ ជាក់ស្តែងមុនឈានដល់ដំណាក់កាលនីតិវិធីបណ្តឹង មេធាវីអាចដើរតួធ្វើជាអ្នកផ្សះផ្សាបាន ប្រសិនបើ

---

[54] សាន់ ជួយ, "នីតិវិធីរដ្ឋប្បវេណី," (ឯកសារជាសៀវភៅ សម្រាប់និស្សិតបរិញ្ញាបត្រ នីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច,គ្មានកាលបរិច្ឆេទ),១៤។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៩៣។

[56] France Code of Civil Procedure, 14 May 1981, Article 72 and article123.

[57] The Code of Civil Procedure of Japan, N$^0$.109, 26 June 1996, Article156.

[58] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ៩៣។

ការព្រមព្រៀងពីភាគី។ ក្នុងករណីដែលដំណើរការនៃរឿងក្តីឈានដល់ដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយនោះ ក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ឱ្យតុលាការត្រូវធ្វើការសាកល្បងផ្សះផ្សាជាដំបូងសិន ប៉ុន្តែប្រសិនបើតុលាការយល់ឃើញថា មិនសមរម្យតុលាការមិនចាំបាច់ធ្វើការផ្សះផ្សាបានដូចគ្នាដូចជាភាគីគ្មានឆន្ទៈ ក្នុងការផ្សះផ្សា ឬ សិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹងមិនអាចអនុញ្ញាតឱ្យចាត់ចែងបានទេ។[59] ប្រសិនបើភាគីបានកំណត់អំពីអត្ថិភាព និង នត្ថិភាពនៃសិទ្ធិ និង កាតព្វកិច្ច តាមរយៈការសះជាហើយភាគីព្រមព្រៀងបិទបញ្ចប់វិវាទ នោះតុលាការនឹងបិទបញ្ចប់រឿងក្តីតាមឆន្ទៈរបស់ភាគីដូចគ្នា ដោយហេតុថាក្រមនីតិវិធីរដ្ឋប្បវេណីមានគោលបំណងធ្វើការកំណត់អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ និង កាតព្វកិច្ចតាមច្បាប់សារធាតុដែលអាចចាត់ចែងបានដោយផ្អែកលើការព្រមព្រៀងរវាងភាគី។

**៣.១.២.៣. ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ពេលដែលបិទបញ្ចប់នីតិវិធីត្រៀមទាញហេតុផល តុលាការ និង ភាគីទាំងសងត្រូវធ្វើការបញ្ជាក់អំពីអង្គហេតុដែលជាចំណុចវិវាទ ដោយតុលាការត្រូវសួរបញ្ជាក់ភាគីទាំងសងខាងអំពីលទ្ធផលនៃការរៀបចំនូវចំណុចវិវាទនេះ ដើម្បីឱ្យមានការឯកភាពគ្នា និងដើម្បីអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធីនៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់។

បន្ទាប់ពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបិទបញ្ចប់ហើយ ភាគីសងខាងមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីបានទៀតនោះទេ។[60] ការហាមឃាត់មិនឱ្យភាគីដាក់នូវមធ្យោបាយតទល់ ឬ ការពារថ្មីដោយយល់ឃើញថា អាចជាការនាំឱ្យមានការយឺតយ៉ាវនៃនីតិវិធី ពិសេសនោះគឺក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា បានជ្រើសយកគោលការណ៍នៃការដាក់មធ្យោបាយតទល់ និង ការពារខ្លួននូវពេលវេលាសមរម្យ ពោលគឺតម្រូវឱ្យភាគីសងខាងដាក់ មធ្យោបាយតទល់ និង ការពារខ្លួននៅមុនពេលបិទបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ត្បិតយ៉ាងនេះក្តីក៏ក្រមនីតិវិធីរដ្ឋប្បវេណីយើងបានលើកលែងលើករណីចំនួន ៣ (បី) ដែលអនុញ្ញាតឱ្យភាគីមានលទ្ធភាពដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនបាន ករណីដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ដែលទាក់ទងទៅនឹងសមត្ថកិច្ចរបស់តុលាការ សមត្ថកិច្ចជំនុំជម្រះ ឬ ការដកហូតចៅក្រមជាដើម ភាគីក៏អាចដាក់បានប្រសិនបើការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួននោះមិនបង្កឱ្យមានការយឺតយ៉ាវដល់នីតិវិធី ជាក់ស្តែងការស្នើសុំឱ្យពិនិត្យភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន ដូចជាឯកសារ ឬ សាក្សីដែលភាគីបាននាំមកជាមួយក្នុងកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ និង ករណីមួយទៀតដែលភាគីធ្វើ

[59] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០៤។

[60] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០៨។

សេចក្តីបញ្ជាក់ដំបូងថាមិនអាចដាក់ភស្តុតាងបាន ដោយការមិនអាចដាក់បាន នេះមិនមែនជាកំហុសធ្ងន់ធ្ងររបស់ខ្លួន។

ក្រៅពីនេះតុលាការ ត្រូវកំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ហើយត្រូវកោះហៅភាគីទាំងសងខាង ដើម្បីចូលរួមក្នុងដំណើរការនៃការទាញហេតុផលផ្ទាល់មាត់នូវកាលបរិច្ឆេទដែលបានកំណត់នៃការទាញហេតុផលនោះ។

## ៣.២.ការទាញហេតុផលផ្ទាល់មាត់

ការទាញហេតុផលផ្ទាល់មាត់ ជានីតិវិធីដែលត្រូវកើតឡើងបន្ទាប់ពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបិទបញ្ចប់ និង ការមកដល់នៃកាលបរិច្ឆេទការទាញហេតុផលផ្ទាល់មាត់ និង វត្តមានរបស់ភាគីទាំងសងខាង។ "ការទាញហេតុផលផ្ទាល់មាត់ គឺជាទម្រង់នៃការជម្រះក្តី ដែលក្នុងនោះសកម្មភាពតុលាការ និងសកម្មភាពរបស់ភាគី ចំពោះរឿងក្តីនោះ ត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និងការស្តាប់សេចក្តីថ្លែងការណ៍នោះនៅសាលសវនាការបើកចំហរជាសាធារណៈ"[61]។ គោលការណ៍សាធារណៈនៃការទាញហេតុផលផ្ទាល់មាត់ គឺជាគោលការណ៍ចាំបាច់មួយក្នុងដំណាក់ការនៃទាញហេតុផលផ្ទាល់មាត់ដែលមានគោលបំណងលុបបំបាត់ការជម្រះក្តីជាសម្ងាត់ដែលអាចមានភាពអយុត្តិធម៌ចំពោះភាគីណាមួយ។ ប៉ុន្តែ ក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ទុកនូវករណីលើកលែងមួយចំនួន ដែលអាចឱ្យតុលាការមានសិទ្ធិអាចមិនប្រើប្រាស់គោលការណ៍សាធាណៈនេះ ប្រសិនបើភាពសាធារណៈនេះបណ្តាលឱ្យខូចខាតប្រយោជន៍សាធារណៈ។[62]

### ៣.២.១.ភាពចាំបាច់នៃការទាញហេតុផលផ្ទាល់មាត់

ជាគោលការណ៍ ការជម្រះក្តីលើបណ្តឹងមួយតុលាការត្រូវតែឆ្លងកាត់នូវការទាញហេតុផលផ្ទាល់មាត់ដើម្បីសម្រេចវិនិច្ឆ័យ និងចេញសាលក្រមលើបណ្តឹង ដែលធានាបាននូវភាពយុត្តិធម៌ចំពោះភាគី ពិសេសដើម្បីឱ្យប្រាកដថាតុលាការដែលចេញសាលក្រមបានស្តាប់ការអះអាងរបស់ភាគីដោយផ្ទាល់។ ម៉្យាងទៀតក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាមានគោលបំណងធានានូវគោលការណ៍ចំពោះមុខ និង ផ្តល់លទ្ធភាពឱ្យភាគីទាំងសងខាងអាចធ្វើសេចក្តីថ្លែងការណ៍អំពីការអះអាងរបស់ពួកគេដោយស្មើភាព និង យុត្តិធម៌។

[61] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, រៀបចំ, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០០៨), ៨៧។

[62] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៥។

### ៣.២.២. សកម្មភាពក្នុងទាញហេតុផលផ្ទាល់មាត់

#### ៣.២.២.១. ការថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល

ជាគោលការណ៍នៃក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ឱ្យភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។[63] សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាសេចក្តីថ្លែងការណ៍សរុបអំពីសកម្មភាពទាំងឡាយដែលបានធ្វើក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផលនោះ ដូចនេះតាមរយៈសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀម ការអះអាងអង្គហេតុ ការដាក់ភស្តុតាង លទ្ធផលនៃការរៀបចំចំណុចវិវាទចាត់ទុកថាបានធ្វើនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ ហើយការធ្វើសម្មភាពទាំងនេះឡើងវិញវាពុំមានភាពចាំបាច់ឡើយ។ នៅពេលធ្វើសេចក្តីថ្លែងការណ៍ ពីលទ្ធផលនៃនីតិវិធីត្រៀម ភាគីដែលធ្វើសេចក្តីថ្លែងការណ៍ត្រូវបញ្ជាក់ឱ្យបានច្បាស់ អំពីអង្គហេតុដែលជាចំណុចវិវាទដែលត្រូវធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់។

#### ៣.២.២.២. ការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួនថ្មី

ដូចបានពន្យល់ពីខាងលើផងដែរថា ក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់ពីគោលការណ៍សមរម្យនៃការដាក់មធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួន ប៉ុន្តែក៏នៅមានករណីលើកលែងចំពោះការដាក់មធ្យោបាយការពារ ឬ តទល់ដែលមិនផ្ទុយពីបញ្ញត្តិដែលមានចែងក្នុងមាត្រា១០៨។ ដូចនេះភាគីអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីបានក្នុងពេលដំណើរការនៃការទាញហេតុផលផ្ទាល់មាត់បាន ប៉ុន្តែមានតែមធ្យោបាយតទល់ ឬ ការពារខ្លួន ដែលពាក់ព័ន្ធទៅនឹងបញ្ហាដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន មធ្យោបាយការពារ ឬ តទល់ ដែលមិនបង្កឱ្យមានការយឺតយ៉ាវខ្លាំងដល់នីតិវិធី និង មធ្យោបាយតទល់ ឬ ការពារខ្លួន ដែលភាគីបានបញ្ជាក់ពីដំបូងថាការមិនអាចដាក់មធ្យោបាយនោះមិនមែនបណ្តាលមកពីកំហុសធ្ងន់ធ្ងរឡើយ។

#### ៣.២.២.៣. ការពិនិត្យភស្តុតាង

ការពិនិត្យភស្តុតាងត្រូវធ្វើឡើងនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលផ្ទាល់មាត់។[64] តុលាការត្រូវធានាឱ្យបាននូវវត្តមានរបស់ភាគីក្នុងចូលរួមនៃដំណើរការនៃការពិនិត្យភស្តុតាងត្រង់ចំណុចនេះ ជាសិទ្ធិនៃបណ្តឹងមូលដ្ឋានមួយរបស់ភាគីក្នុងការតទល់ និងការពារខ្លួន ប៉ុន្តែការពិនិត្យភស្តុតាងនេះក៏តុលាការអាចធ្វើទៅបានដែរបើទោះបីជាពុំមានវត្តមានរបស់ភាគីណាម្ខាង ឬ ទាំងសងខាងនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ដោយហេតុផលណាមួយក្តី។[65]

---

[63] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៦។

[64] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១២៧។

[65] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១២៨។

បន្ទាប់ពីតុលាការបានធ្វើការពិនិត្យភស្តុតាង នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ ហើយ យល់ឃើញថាចាំបាច់ តុលាការធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផលម្តងទៀតបាន។[66]

**៣.២.៣.ការបញ្ចប់ការទាញហេតុផលផ្ទាល់មាត់**

ក្រោយពេលបញ្ចប់ការពិនិត្យភស្តុតាងរួច ហើយតុលាការយល់ឃើញថាលទ្ធផលនៃការទាញហេតុផលផ្ទាល់មាត់មានភាពគ្រប់គ្រាន់ដល់ការវិនិច្ឆ័យហើយនោះ តុលាការត្រូវបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ ហើយចេញសាលក្រមមួយដែលត្រូវវិនិច្ឆ័យទៅលើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទាររបស់ដើមចោទដែលបានសរសេរក្នុងពាក្យបណ្តឹង។

[66] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៦។

# ជំពូកទី ៤

# របកគំហើញថ្មី

## ៤.១.ចំណុចដែលចាំបាច់ត្រូវសរសេរបញ្ជាក់នៅក្នុងពាក្យបណ្តឹងរដ្ឋប្បវេណីសម្រាប់សាលាដំបូង

តាមគោលការណ៍នៃពាក្យបណ្តឹង ដែលអនុលោមតាម មាត្រា ៧៥ កថាខណ្ឌទី ២ ៣ និង ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺត្រូវសរសេរ ៖

១.ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី, ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

២.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។

៣.អង្គហេតុដែលជាមូលហេតុនៃការទាមទារ និង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាងក្នុងអង្គហេតុទាំងមូល។

ការសរសេរពីខ្លឹមសារនៃសាលក្រមដែលទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។ អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងតាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាងក្នុងអង្គហេតុទាំងមូលនេះ គឺត្រូវផ្អែកទៅតាមប្រភេទនៃបណ្តឹង ៖

១.បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក និងតាវកាលិកតប

២.បណ្តឹងទាមទារឱ្យបង្កើតផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

៣.ប្រភេទបណ្តឹងទាមទារឱ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្ត ។

## ៤.២.ទម្រង់ពាក្យបណ្តឹង និង ចំណុចត្រូវសរសេរក្នុងពាក្យបណ្តឹងដែលកំពុងអនុវត្ត និងប្រើប្រាស់ជាទូទៅសម្រាប់តុលាការ

–ទម្រង់ទី ១

១.ខ្ញុំបាទ/នាងខ្ញុំឈ្មោះ......................អាយុ............ភេទ...............សញ្ជាតិ.............មានទីលំនៅបច្ចុប្បន្នផ្ទះលេខ..........ភូមិ..................ឃុំ/សង្កាត់...................ក្រុង/ខេត្ត................................។

២.កម្មវត្ថុ ៖ សុំប្តឹងពីឈ្មោះ...........................................................................................។

៣.យោង ៖ ............................................................................................................។

៤.តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូនលោកប្រធានមេត្តាជ្រាបថា........................។

៥.សំណូមពរ

៦.អាស្រ័យហេតុដូចបានរៀបរាប់ជូនខាងលើ សូមលោកប្រធាន មេត្តាជួយរកយុត្តិធម៌ដល់ខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

–ទម្រង់ទី ២

១.ខ្ញុំបាទ/នាងខ្ញុំឈ្មោះ......................អាយុ...........ភេទ..............សញ្ជាតិ.............មានទីលំនៅបច្ចុប្បន្នផ្ទះលេខ..........ភូមិ.................ឃុំ/សង្កាត់..................ក្រុង/ខេត្ត...............................។

២.កម្មវត្ថុ ៖ សុំឱ្យតុលាការចេញសាលក្រមទទួលស្គាល់ .........................................................។

៣.ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូនតុលាការមេត្តាជ្រាបថា..........................................................។

៤.អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធាន មេត្តាចេញសាលក្រមតាមកម្មវត្ថុខាងលើ ដោយក្តីអនុគ្រោះ។

–ទម្រង់ទី ៣

១.ខ្ញុំបាទ/នាងខ្ញុំឈ្មោះ......................អាយុ...........ភេទ..............សញ្ជាតិ.............មានទីលំនៅបច្ចុប្បន្នផ្ទះលេខ..........ភូមិ.................ឃុំ/សង្កាត់..................ក្រុង/ខេត្ត...............................។

២.កម្មវត្ថុ ៖ ប្តឹងសុំឈប់រស់នៅជាអនីតិសង្វាសពីប្តីឈ្មោះ................អាយុ........សញ្ជាតិ...........មុខរបរ..............មានទីលំនៅផ្ទះលេខ............ភូមិ..............ឃុំ/សង្កាត់...........ក្រុង/ខេត្ត........។

៣.តបតាមកម្មវត្ថុខាងលើ នាងខ្ញុំ សូមជម្រាបជូន ឯកឧត្តមប្រធាន មេត្តាជ្រាបថា.........................។

៤.អាស្រ័យដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ សូម ឯកឧត្តមប្រធាន មេត្តាជួយដោះស្រាយបណ្តឹងសុំឈប់រស់នៅជាអនីតិសង្វាសរបស់នាងខ្ញុំដោយក្តីអនុគ្រោះ។

–ទម្រង់ទី ៤

១.ដើមចោទ ៖ យើងខ្ញុំទាំងអស់គ្នាជាម្ចាស់ដី មានទីតាំងស្ថិតនៅភូមិ......................ឃុំ.............ស្រុក...................ខេត្ត...............................។

២.ចុងចម្លើយ ៖ ក្រុមហ៊ុនស៊ីធីម៉ាត មានទីតាំងស្ថិតនៅភូមិ..........................ឃុំ..................ស្រុក.................ខេត្ត..............................ដែលមានលោក......................ជានាយកក្រុមហ៊ុន។

៣.កម្មវត្ថុ ៖ សុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម

- សុំបដិសេធចោលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។
- សុំទទួលស្គាល់ការកាន់កាប់ដីរបស់យើងខ្ញុំទាំង១៦៦គ្រួសារ មានទំហំ ៨១ ហិកតា។

៤.តបតាមកម្មវត្ថុខាងលើ យើងខ្ញុំ សូមជម្រាបលោកប្រធាន មេត្តាជ្រាបថា :

៥.អាស្រ័យហេតុនេះ សូមលោកប្រធាន មេត្តាចេញសាលក្រមសម្រេចតាមការស្នើសុំ ដូចមានក្នុងកម្មវត្ថុខាងលើដោយក្តីអនុគ្រោះ។

–ទម្រង់ទី ៥

១.ដើមចោទឈ្មោះ............................អាយុ..........ភេទ..........សញ្ជាតិ....................មានទីលំនៅបច្ចុប្បន្នផ្ទះលេខ......ភូមិ...................ឃុំ/សង្កាត់.....................ក្រុង/ខេត្ត................................។

២.ចុងចម្លើយឈ្មោះ...........................អាយុ..........ភេទ...........សញ្ជាតិ..................មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......ភូមិ................ឃុំ/សង្កាត់.....................ក្រុង/ខេត្ត..................................។

៣.កម្មវត្ថុបណ្តឹង៖ សុំសិទ្ធិគ្រប់គ្រងកាន់កាប់ដីទំហំ ១៧៦១ ម៉ែត្រក្រឡា...................................។

៤.អង្គហេតុចាំបាច់បញ្ជាក់ការទាមទារ .......................................................................។

៥.មូលហេតុនៃការទាមទារ ...................................................................................។

៦.អាស្រ័យដូចនាងខ្ញុំបានជម្រាបជូន ឯកឧត្តមប្រធាន ជ្រាបដូចខាងលើនេះសូមឯកឧត្តមប្រធានមេត្តាជួយរកយុត្តិធម៌ដល់នាងខ្ញុំដោយក្តីអនុគ្រោះ។

–ទម្រង់ទី ៦

១.ដើមចោទឈ្មោះ............................អាយុ..........ភេទ............សញ្ជាតិ..................មានទីលំនៅបច្ចុប្បន្នផ្ទះលេខ......ភូមិ...................ឃុំ/សង្កាត់.....................ក្រុង/ខេត្ត................................។

២.ចុងចម្លើយឈ្មោះ...........................អាយុ..........ភេទ............សញ្ជាតិ..................មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......ភូមិ................ឃុំ/សង្កាត់.....................ក្រុង/ខេត្ត..................................។

៣.កម្មវត្ថុ ៖ សុំប្តឹងយកដីមកគ្រប់គ្រងកាន់កាប់វិញ.................................................................។

៤.មូលហេតុនៃការទាមទារ ...................................................................................។

៥.អាស្រ័យដូចនាងខ្ញុំបានជម្រាបជូន ឯកឧត្តមប្រធាន ជ្រាបដូចខាងលើនេះសូមឯកឧត្តមប្រធានមេត្តាជួយរកយុត្តិធម៌ដល់នាងខ្ញុំដោយក្តីអនុគ្រោះ។

# សេចក្តីសន្និដ្ឋាន

នៅក្នុងកិច្ចនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណី នៅតែជាបញ្ហាចោទទូទៅមួយចំពោះប្រជាជនកម្ពុជា ជាពិសេសចំពោះបញ្ហានៃការរៀបចំពាក្យបណ្តឹងមួយដែលត្រឹមត្រូវ និង ស្របតាមលក្ខខណ្ឌដែលមានកំណត់។ តាមមាត្រា ១ ក្រមរដ្ឋប្បវេណី និងមាត្រា ១ និង មាត្រា ២ ក្រមនីតិវិធីរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងខ្វះលក្ខខណ្ឌច្បាប់ជាច្រើនដូចបានដាក់បង្ហាញក្នុងរបាយការណ៍នេះ វាមិនជាកំហុសរបស់រដ្ឋនោះទេ ពោលគឺជាកំហុសផ្ទាល់របស់ភាគី ដែលគូក្តីពុំបានព្យាយាមអនុវត្តសិទ្ធិតាមច្បាប់របស់ខ្លួន។ ពាក្យបណ្តឹងរដ្ឋប្បវេណីត្រូវបានកំណត់ឱ្យមានលក្ខខណ្ឌត្រឹមត្រូវតាមបញ្ញត្តិមាត្រា ៧៥ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា។ ការសរសេរពាក្យបណ្តឹងត្រូវមានការកំណត់អំពីសមាសភាពរបស់ភាគីដែលជាដើមចោទ ឬ អ្នកដាក់ពាក្យប្តឹង និង ចុងចម្លើយ ឬ អ្នកដែលត្រូវគេប្តឹង។ ម៉្យាងវិញទៀតនៅក្នុងពាក្យបណ្តឹងត្រូវមានសរសេរអំពីទីកន្លែងស្នាក់នៅរបស់ភាគីទាំងសងខាង ហើយភាគីដែលជាអ្នកដាក់ពាក្យបណ្តឹងត្រូវសរសេរអំពីព័ត៌មានដែលចាំបាច់ក្នុងការទាមទារ ដើម្បីឱ្យតុលាការចេញសាលក្រមតាមការទាមទាររបស់ខ្លួន។ ជាក់ស្តែងក្រមនីតិវិធីរដ្ឋប្បវេណី បានបញ្ញត្តិអំពីចំណុចដែលត្រូវសរសេរបញ្ជាក់ក្នុងពាក្យបណ្តឹងសម្រាប់សាលាដំបូង ដោយអនុលោមតាម មាត្រា ៧៥ កថាខណ្ឌទី ២ ៣ និង ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ផ្ទុយពីនេះនៅក្នុងការអនុវត្តជាក់ស្តែង ភាគីនៅតែសរសេរពាក្យបណ្តឹងតាមរបៀបចាស់ដែលមើលទៅហាក់បីដូចជានាំឱ្យមានការប្រឈមជាមួយនឹងការបាត់បង់សិទ្ធិរបស់ភាគីដែលជាអ្នកប្តឹង និង ចុងចម្លើយខាតបង់ពេលវេលា ថវិកា និង យឺតយ៉ាវដល់ដំណើរការនីតិវិធីរបស់តុលាការ។

ដូចនេះហើយការសរសេរពាក្យបណ្តឹងត្រូវធ្វើឡើងតាមបញ្ញត្តិ មាត្រា ៧៥ ក្រមនីតិវិធីរដ្ឋប្បវេណីដោយជៀសវាងបន្តនូវការអនុវត្តតាមទម្លាប់ដែលផ្ទុយពីគោលការណ៍ច្បាប់។

# អនុសាសន៍

ពលរដ្ឋទាំងឡាយនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា បើគិតថាសិទ្ធិ និង ផលប្រយោជន៍របស់ខ្លួនត្រូវបានអ្នកដទៃរំលោភបំពាន នោះពួកគេអាចស្វែងរកការអន្តរាគមន៍ពីតុលាការបានស្របតាមសិទ្ធិពឹងពាក់តុលាការដែលមានចែងក្នុងរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣។ ក្នុងករណីនេះបុគ្គលដែលបានទទួលរងនូវការរំលោភបំពានសិទ្ធិអាចធ្វើការដោះស្រាយតាមផ្លូវបណ្ដឹងទៅតុលាការដែលមានសមត្ថកិច្ចបានតាមរយៈការពិគ្រោះយោបល់ជាមុនជាមួយមេធាវី ឬ បុគ្គលដែលយល់ដឹងអំពីនីតិវិធីបណ្ដឹងរបស់តុលាការកម្ពុជា។ យោងតាមមាត្រា ៧៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ បានកំណត់អំពីការសរសេរពាក្យបណ្ដឹង និងលក្ខខណ្ឌចាំបាច់មួយចំនួនដែលតម្រូវឱ្យមានក្នុងពាក្យបណ្ដឹង។

ជាទិដ្ឋភាពជាក់ស្ដែងក្នុងសង្គមកម្ពុជាបច្ចុប្បន្នកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ គឺនៅមានកម្រិតនៅឡើយលើបញ្ហាផ្លូវច្បាប់ មិនមែនមានតែលើបញ្ហាក្នុងការសរសេរពាក្យបណ្ដឹងឱ្យស្របទៅតាមមាត្រា ៧៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦។ ស្ថាប័នដែលអនុវត្តអំណាចយុត្តាធិការរបស់កម្ពុជា គួរពិនិត្យរាល់ពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋដែលបានដាក់ឱ្យទៅ និង ធ្វើការដោះស្រាយ ហើយក្នុងករណីពិនិត្យឃើញថាពាក្យបណ្ដឹងណាមួយខុសពីលក្ខខណ្ឌតម្រូវក្នុងមាត្រា ៧៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ តុលាការគួរពិចារណាបន្ថែមនូវចំណុចមួយទៀត មិនត្រឹមតែឱ្យបុគ្គលអ្នកដាក់ពាក្យបណ្ដឹងធ្វើការកែតម្រូវបណ្ដឹងរបស់ខ្លួនឡើងវិញនោះទេ គឺគួរតែមានអ្នកប្រឹក្សាយោបល់ពាក់ព័ន្ធនឹងការដាក់ពាក្យបណ្ដឹង។

ក្រៅពីនេះរាជរដ្ឋាភិបាលកម្ពុជា គួរបង្កើតនូវយន្តការផ្សេងៗក្នុងការផ្សព្វផ្សាយ អប់រំ ប្រឹក្សាយោបល់ជូនប្រជាពលរដ្ឋអំពីលំហូរនៃកិច្ចនីតិវិធីរឿងក្ដីរដ្ឋប្បវេណីតាមប្រព័ន្ធសារអេឡិចត្រូនិកជាប្រចាំ ឬ បង្កើតក្រុមគ្រូបង្គោលជំនាញថ្នាក់មូលដ្ឋានបន្ថែម ដើម្បីដឹកនាំចូលរួមផ្សព្វផ្សាយឱ្យបានស៊ីជម្រៅនូវចំណេះដឹងផ្នែកច្បាប់ដែលអាចជួយឱ្យប្រជាពលរដ្ឋអាចយល់ដឹងបានគ្រប់ៗគ្នា។

# គន្ថនិទ្ទេស

## ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ០៩ មិថុនា ២០១០។

ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ច្បាប់ស្តីពី លក្ខន្តិកៈមេធាវី, លេខ នស/រកម/០៨៩៥/០៦, ១៥ មិថុនា ១៩៩៥។

ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ២៦ មេសា ២០១០។

ប្រកាសស្តីពីការកែសម្រួលឧបសម្ព័ន្ធ១ និង ឧបសម្ព័ន្ធ៤ នៃប្រកាសលេខ ២៨ កយ ប្រក,០៧ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពី ប្រភេទពាក្យសុំដែលតម្រូវឱ្យបង់ពន្ធ ចំនួនទឹកប្រាក់នៃប្រាក់ពន្ធដាក់ពាក្យសុំ និង ចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្តី និង មាត្រាដ្ឋាន សម្រាប់គណនាប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និង តម្លៃកម្មវត្ថុនៃបណ្តឹង, លេខ ៥៤ កយប្រក/០៩, ២២ មិថុនា ២០០៩។


## ឯកសារជាភាសាខ្មែរ


Mori, Tomoya. "មូលដ្ឋានគ្រឹះនៃការទទួលស្គាល់អង្គហេតុ." ឯកសារជា Power Point សម្រាប់ការបណ្តុះបណ្តាលដើម្បីជួយក្នុងការផ្សព្វផ្សាយក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា លើកទី៣, ២០១៤។

ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. រៀបចំ. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភាគ១, នីតិវិធីបណ្តឹង.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៨។

ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. រៀបរៀង. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី*, ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៧។

សាន់ ជួយ. "នីតិវិធីរដ្ឋប្បវេណី." ឯកសារជាសៀវភៅ សម្រាប់និស្សិតបរិញ្ញាបត្រ នីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

ហ៊ី សោភា. "នីតិវីធីរដ្ឋប្បវេណី." ឯកសារជាសៀភៅ សម្រាប់និស្សិតបរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច,គ្មានកាលបរិច្ឆេទ។

ហាប់ ផល្លី. វិធីសាស្ត្រស្រាវជ្រាវ និង ការសរសេរបែបសិក្សា, បោះពុម្ពលើកទី២ ភ្នំពេញ៖ ឌេយ & ណាយថ៍ ព្រីនធីង, ២០១៩។

អ៊ុំ ប៉ូលី. "នីតិវិធីរដ្ឋប្បវេណី." ឯកសារជា PDF សម្រាប់បង្រៀននៅ សាកលវិទ្យាល័យ បញ្ញាសាស្រ្ត,២០១០។

## ឯកសាជាភាសាបរទេស

France Code of Civil Procedure [ក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសបារាំង]. 14 ឧសភា 1981។

The Code of Civil Procedure of Japan [ក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសជប៉ុន]. លេខ 109, 26 មិថុនា 1996។

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១**

១–ទម្រង់បណ្តឹងសម្រាប់សាលាដំបូង
ខេត្ត/ក្រុង ស្របតាមលក្ខខណ្ឌច្បាប់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យបណ្តឹង

គោរពជូនប្រធានតុលាការក្រុងភ្នំពេញ

–ដើមចោទឈ្មោះ.....................ភេទ.........ថ្ងៃខែឆ្នាំកំណើត.....................អាសយដ្ឋានផ្ទះលេខ.........ឃុំ/សង្កាត់.........
ខណ្ឌ......................ក្រុង/រាជធានី...............................។

–អ្នកតំណាងដោយអាណត្តិរបស់ដើមចោទឈ្មោះ..........................អាសយដ្ឋានផ្ទះលេខ......ឃុំ/សង្កាត់....................
ខណ្ឌ.....................ក្រុង/រាជធានី ................................។

–កន្លែងដែលត្រូវធ្វើការបញ្ជូន។

–ចុងចម្លើយឈ្មោះ.....................ភេទ.........ថ្ងៃខែឆ្នាំកំណើត...................អាសយដ្ឋានផ្ទះលេខ.......ឃុំ/សង្កាត់...........
ខណ្ឌ......................ក្រុង/រាជធានី...............................។

–ទឹកប្រាក់ដែលជាកម្មវត្ថុនៃបណ្តឹង................................។

–ពន្ធដាក់ពាក្យបណ្តឹង.................................................។

–ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ៖.............................................................................
.............................................................................................................................................................។

–អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ៖.....................................................................................................
.............................................................................................................................................................។

–អង្គហេតុដែលជាមូលហេតុនៃការទាមទារ និង អង្គហេតុពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ៖...........
.............................................................................................................................................................។

ភ្នំពេញ, ថ្ងៃទី ...... ខែ .............. ឆ្នាំ .................

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ

ភ្ជាប់មកជាមួយនូវ ៖

១–ភស្តុតាង

–លិខិត...........................

២–លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

២-រូបមន្តនៃពាក្យបណ្តឹងសម្រាប់សាលាដំបូង
រៀបចំដោយសាលាភូមិន្ទចៅក្រមនិងទីភ្នាក់ងារ
សហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន JICA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យបណ្តឹង

គោរពជូនប្រធានតុលាការក្រុងភ្នំពេញ

-ដើមចោទ ខៀវ អាត ភេទប្រុស អាយុ ៤៦ឆ្នាំ អត្តសញ្ញាណប័ណ្ណលេខ ១១១១ អាសយដ្ឋានផ្ទះលេខ ១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-អ្នកតំណាងដោយអាណត្តិដើមចោទ មាស ពេជ្រ អាសយដ្ឋាន ooooo, xxxxx, ភ្នំពេញ។

-កន្លែងដែលត្រូវធ្វើការបញ្ជូន។

-ចុងចម្លើយ សុក បូរា ភេទប្រុស អាយុ ៤៦ឆ្នាំ អត្តសញ្ញាណប័ណ្ណលេខ ២២២២ អាសយដ្ឋានផ្ទះលេខ ៣៤ សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-ទឹកប្រាក់ដែលជាកម្មវត្ថុនៃបណ្តឹង ៨.០០០ ដុល្លារ (ប្រាំបីពាន់ដុល្លារអាមេរិក)។

-ពន្ធដាក់ពាក្យបណ្តឹង ២៥៤.០០០ រៀល ( ម្ភៃប្រាំម៉ឺនបួនពាន់រៀល)។

ទី១-សាលក្រមដែលទាមទារដោយដើមចោទ

ដើមចោទទាមទារឱ្យតុលាការចេញសាលក្រម និង ទាមទារនូវការប្រកាសអនុវត្តជាបណ្តោះអាសន្ន ៖

ក-ចុងចម្លើយត្រូវបង់ទៅឱ្យដើមចោទនូវទឹកប្រាក់ចំនួន ៩.៦០០ ដុល្លារ ព្រមទាំងទឹកប្រាក់ ចំនួន ២០% ក្នុងមួយឆ្នាំនៃប្រាក់ ៨.០០០ ដុល្លារ ក្នុងទឹកប្រាក់ ៩.៦០០ ដុល្លារ នេះដែរដោយគិតពីថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០០៦ រហូតដល់ថ្ងៃដែលបានបង់ចប់សព្វគ្រប់។

ខ-ចុងចម្លើយត្រូវទទួលរ៉ាប់រងនូវប្រាក់ប្រដាប់ក្តី។

ទី២-អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ៖

ក-ការទាមទារឱ្យសងប្រាក់កំចីចំនួន ៨.០០០ ដុល្លារ ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើងរវាងដើមចោទ និងចុងចម្លើយនៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៤

ខ-ការទាមទារការប្រាក់ចំនួន ២ឆ្នាំ គឺ ១៦០០ ដុល្លារ ដែលជាការគណនាតាមអត្រាការប្រាក់ ១០% ក្នុងមួយឆ្នាំដែលបានសន្យាពេលបង្កើតកិច្ចសន្យា (ក) ខាងលើនេះ។

គ–ការទាមទារការប្រាក់នៃការយឺតយ៉ាវ ២០% ក្នុងមួយឆ្នាំ ដោយគណនាពីថ្ងៃទី២ ខែ មិថុនា ឆ្នាំ ២០០៦ ដែលជាថ្ងៃបន្ទាប់នៃកាលកំណត់សង ដែលបានសន្យាពេលបង្កើតកិច្ចសន្យា (ក) ខាងលើនេះរហូតដល់ថ្ងៃដែលបានសងចប់សព្វគ្រប់។

ទី៣–អង្គហេតុដែលជាមូលហេតុនៃការទាមទារ និង អង្គហេតុពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ៖

ប្រហែលជាខ្ទង់ ខែ មេសា ឆ្នាំ ២០០៤ ចុងចម្លើយបានសុំខ្ចីប្រាក់ ៨.០០០ ដុល្លារ ពីដើមចោទ ដើម្បីជួសជុលផ្ទះរបស់ខ្លួន។

ដោយសារតែជាមិត្តតាំងពីយូរណាស់មកហើយ ដើមចោទក៏បានយល់ព្រមឱ្យចុងចម្លើយខ្ចី ហើយនៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំដដែលនោះ ក៏បានបង្កើតកិច្ចសន្យាឱ្យចុងចម្លើយខ្ចីប្រាក់ ៨.០០០ដុល្លា ដោយកំណត់ឱ្យសងនៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០៦ ហើយនៅថ្ងៃធ្វើកិច្ចសន្យានោះដើមចោទបានប្រគល់ប្រាក់ ៨.០០០ ដុល្លានោះទៅឱ្យចុងចម្លើយ ដោយផ្អែកលើកិច្ចសន្យានោះ។ ចុងចម្លើយបានព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខា អំពីការបង់កាប្រាក់ ១០% ក្នុងមួយឆ្នាំ និងរយៈពេលចំនួន ២ឆ្នាំ ដោយគិតរហូតដល់កាលកំណត់សង។ ម្យ៉ាងវិញទៀត ចុងចម្លើយបានព្រមព្រៀងអំពីការបង់កាប្រាក់នៃការយឺតយ៉ាវ ២០% ក្នុងមួយឆ្នាំ នៅក្នុងករណីដែលចុងចម្លើយមិនបានសងតាមកាលកំណត់នេះ។ (ភស្តុតាង X1)។

លុះដល់ថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០៦ ដែលជាកាលកំណត់សងនោះ ចុងចម្លើយបានមកផ្ទះដើមចោទ តែគាត់បាននិយាយថា គាត់ត្រូវកាប្រាក់ដើម្បីព្យាបាលជម្ងឺឪពុករបស់គាត់ ហើយមិនបានសងទាំងប្រាក់កំចីទាំងកាប្រាក់។ រហូតដល់សព្វថ្ងៃនេះចុងចម្លើយនៅមិនទាន់បានសងនៅឡើយទេ។

ភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ

មាស ពេជ្រ

ភ្ជាប់មកជាមួយនូវ ៖

១–ភស្តុតាង X1

–លិខិតនៃកិច្ចសន្យាខ្ចីប្រាក់

២–លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

**ឧបសម្ព័ន្ធទី៣**

១–ទម្រង់ពាក្យបណ្តឹងកំពុង
អនុវត្តទូទៅ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យបណ្តឹង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..........................អាយុ.........ភេទ.............សញ្ជាតិ...................មានអាសយដ្ឋាន ផ្ទះលេខ........ភូមិ.......................ឃុំ/សង្កាត់...................ក្រុង/ខេត្ត..................។

សូមគោរពចូលមក
លោកប្រធានសាលាដំបូង ខេត្ត/ក្រុង..........................

កម្មវត្ថុ ៖ សុំប្តឹងឈ្មោះ.............................អាយុ.........ភេទ...................សញ្ជាតិ................មានអាសយដ្ឋាន ផ្ទះលេខ...........ភូមិ..........................ឃុំ/សង្កាត់.....................ក្រុង/ខេត្ត........................។

យោង ៖ ........................................................................................................................
........................................................................................................................។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូនលោកប្រធានមេត្តាជ្រាបដូចតទៅ៖

........................................................................................................................
........................................................................................................................។

សំណូមពរ៖

........................................................................................................................
........................................................................................................................។

អាស្រ័យហេតុដូចបានរៀបរាប់ជូនខាងលើ សូមលោក ប្រធាន មេត្តាជួយរកយុត្តិធម៌ ដល់ខ្ញុំបាទដោយក្តីអនុគ្រោះ។

សូម លោក ប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅថ្ងៃទី............ ខែ ...........ឆ្នាំ ២០១.....

ស្នាមម្រាមដៃ

២–ពាក្យបណ្ដឹងរបស់ឈ្មោះ
ជូ ស៊ុវីឡែត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យបណ្ដឹង

– ដើមចោទឈ្មោះ ជូ ស៊ុវីឡែត ភេទស្រី អាយុ ២៥ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ២២ ផ្លូវលេខ ១១០ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

– ចុងចម្លើយឈ្មោះ ម៉ុង លឹមម៉ាប់ ភេទប្រុស ឆ្នាំកំណើត ១៩៥៩ អត្តសញ្ញាណប័ណ្ណលេខ ០២០៥០១០៤១ ទីកន្លែងកំណើត ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ឪពុកឈ្មោះ លឹម ម៉េងគន់ ម្ដាយឈ្មោះ លាង ហ៊ុយខេង និង ប្រពន្ធឈ្មោះ សុខ មិុញ ឆ្នាំកំណើត ១៩៥៩ ទីកន្លែងកំណើត ស្រុក កណ្ដាលស្ទឹង ខេត្តកណ្ដាល ឪពុកឈ្មោះ សូ សែម ម្ដាយឈ្មោះ ហោ ស្រ៊ុន អាសយដ្ឋានភូមិព្រែកតាពៅ ឃុំដើមមៀន ស្រុកតាខ្មៅ ខេត្តកណ្ដាល។

សូមគោរពជូន
ឯកឧត្តម ប្រធានសាលាដំបូងរាជធានីភ្នំពេញ

*សូមទានជ្រាប។*

ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:

១–ឱ្យចុងចម្លើយផ្ទេរសិទ្ធិនូវអចលនវត្ថុចំនួន ៦ឡូតិ៍ (១៤C, ១៥C, ១៦C, ១៧C, ១៨C, ១៩C) ដែលមានទំហំដីសរុប ៥៤៩ម៉ែត្រការ៉េស្ថិតនៅផ្លូវលំ ភូមិដំណាក់ធំ២ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមាន ជ័យ រាជធានីភ្នំពេញ ដែលមានក្នុងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០៦០១០១-១០២៤ សន្លឹកផែនទីលេខ ៥៩៣២-១១៨៣C ៣ លេខក្បាលដី ១០២៤ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៩ មកឱ្យនាងខ្ញុំវិញជាដើមចោទ។

២–ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

<u>យោង</u> ៖ លិខិតផ្ទេរសិទ្ធិគ្រប់គ្រង ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៩

– លិខិតផ្ទេរសិទ្ធិគ្រប់គ្រង ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ដូចបានជម្រាបជូនខាងលើ នាងខ្ញុំសូមជម្រាបជូន ឯកឧត្តម ប្រធានមេត្តាជ្រាបថា: ម្ដាយនាងខ្ញុំឈ្មោះ ផៃ ធន់នី បានទិញដី និងផ្ទះលេខចំនួន ៦ឡូតិ៍ (១៤C, ១៥C, ១៦C, ១៧C, ១៨C, ១៩C) ដែលមានទំហំដីសរុប ៥៤៩ម៉ែត្រការ៉េស្ថិតនៅផ្លូវលំ ភូមិដំណាក់ធំ២ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ពីចុងចម្លើយតាំងពីឆ្នាំ ២០០៩ មកម្ល៉េះ។

បន្ទាប់ពីម្ដាយនាងខ្ញុំបានទិញ និង បានប្រគល់ប្រាក់គ្រប់ចំនួនរួចមក ចុងចម្លើយបានធ្វើលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និង ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ និង លិខិតចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០០៩ ដោយមានប្រថាប់ត្រា

ដោយចៅសង្កាត់ស្ទឹងមានជ័យផងដែរជាភស្តុតាងស្រាប់ ប៉ុន្តែចុងម្លើយមិនទាន់ផ្ទេរសិទ្ធិក្នុងវិញ្ញាបនប័ត្រសំគាល់អចលនវត្ថុឱ្យម្តាយ នាងខ្ញុំ នៅឡើយទេ ដោយសារចុងចម្លើយ ជំពាក់បំណុលគេច្រើន រត់គេចខ្លួនដោយបច្ចុប្បន្នពុំដឹងជាចុងចម្លើយរស់នៅកន្លែងណាឡើយ។

តាំងពីម្តាយនាងខ្ញុំបានទិញពីចុងចម្លើយរួចមកម្តាយ នាងខ្ញុំ បានគ្រប់គ្រង ប្រើប្រាស់នៅលើដីនេះតាំងពីពេលទិញ (២០០៩) រហូតមកដល់បច្ចុប្បន្ននេះ។

ដោយហេតុថាចុងចម្លើយបានលក់ដីនិងបានទទួលប្រាក់គ្រប់ចំនួនពីម្តាយនាងខ្ញុំរួចរាល់ហើយ ហើយម្តាយនាងខ្ញុំបានផ្ទេរសិទ្ធិគ្រប់គ្រង និង ប្រើប្រាស់ដីមកនាងខ្ញុំរួចហើយ នាងខ្ញុំ ប្តឹងសុំតុលាការចេញសាលក្រមសម្រេចឱ្យចុងចម្លើយផ្ទេរសិទ្ធិនូវអចលនវត្ថុចំនួន ៦ឡូតិ៍ (១៤C, ១៥C, ១៦C, ១៧C, ១៨C, ១៩C) ដែលមានទំហំដីសរុប ៥៤៩ម៉ែត្រការ៉េ ស្ថិតនៅផ្លូវលំ ភូមិដំណាក់ធំ២ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានក្នុងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០៦០១០១-១០២៤ សន្លឹកផែនទីលេខ ៥៩៣២–១១៨៣C៣ លេខក្បាលដី ១០២៤ ចុះថ្ងៃទី២០ ខែ មីនា ឆ្នាំ ២០០៩ មកឱ្យនាងខ្ញុំជាដើមចោទ។

អាស្រ័យដូចបានជម្រាបខាងលើ សូម ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ មេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ។

សូម ឯកឧត្តមប្រធាន ទទួលនូវការគោរពពីនាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៤

ស្នាមមេដៃស្តាំ

ជូ សុរិទ្បេត

៣-ពាក្យបណ្តឹងរបស់ឈ្មោះ
អ៊ឹង ដាណែត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យបណ្តឹង

នាងខ្ញុំឈ្មោះ អ៊ឹង ដាណែត អាយុ ៣៣ ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរ ជាងអ៊ុតសក់ មានទីលំនៅ បច្ចុប្បន្នផ្ទះលេខ ៩៤ ផ្លូវលំ ភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

សូមគោរពជូន
ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

*សូមទានជ្រាប។*

កម្មវត្ថុ ៖ ប្តឹងសុំឈប់រស់នៅជាអនីតិសង្វាសពីប្តីឈ្មោះ គឹម ពៅ អាយុ ៣៥ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរ បុគ្គលិកសណ្ឋាគារកាំបូឌីយ៉ាណា មានទីលំនៅសព្វថ្ងៃផ្ទះលេខ ៩៤ ផ្លូវលំ ភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

តបតាមកម្មវត្ថុខាងលើ នាងខ្ញុំសូមជម្រាបជូន ឯកឧត្តមប្រធាន មេត្តាជ្រាបថា នាងខ្ញុំ ប្តឹងមកតុលាការសុំឱ្យចេញសាលក្រមឈប់រស់នៅជាអនីតិសង្វាសជាមួយឈ្មោះ គឹម ពៅ ដោយមូលហេតុថាការរស់នៅមិនចុះសម្រុងជាមួយគ្នា មិនយល់ចិត្តគ្នាទៅវិញទៅមក ចេះតែឈ្លោះប្រកែកគ្នាជាញឹកញាប់ ការរស់នៅជាមួយគ្នាគ្មានសេចក្តីសុខ និងអស់មនោសញ្ចេតនាជាប្តី ប្រពន្ធតទៅទៀតដែរ ហើយក្រោយពីរៀបការរួចប្តី ប្រពន្ធនាងខ្ញុំ ពុំបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នោះទេ។ ចំពោះទ្រព្យសម្បត្តិរួម មានផ្ទះដែលរស់នៅសព្វថ្ងៃ គឺនាងខ្ញុំ និង ប្តីបានព្រមព្រៀងប្រគល់ឱ្យកូនទាំងពីរនាក់ ហើយនាងខ្ញុំសុំសិទ្ធិគ្រប់គ្រងថែរក្សាបណ្តោះអាសន្នចាំរហូតដល់កូនទាំងពីរនាក់មាននីតិភាព។ ចំពោះបំណុលរួមមានជំពាក់ប្រាក់ធនាគារស្ថាបនាលីមីធីត។

នាងខ្ញុំ សុំបញ្ជាក់ថា ក្រោយពេលរៀបអាពាហ៍ពិពាហ៍រួច គឺមានកូនពីរនាក់ ទី១ ឈ្មោះ ផេត ថារ៉ាត់ ភេទប្រុស កើតថ្ងៃទី ២១-០៧-២០០១ ទី២ ឈ្មោះ ផេត សិរីមុនី ភេទស្រី កើតថ្ងៃទី ១៦-០៧-២០០៤ គឺនាងខ្ញុំសុំសិទ្ធិគ្រប់គ្រងថែរក្សាទាមទារអាហារកិច្ចចិញ្ចឹមកូនក្នុងមួយខែ ៤០០ដុល្លារអាមេរិក។

អាស្រ័យដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ សូម ឯកឧត្តមប្រធាន មេត្តាជួយដោះស្រាយបណ្តឹងសុំឈប់រស់នៅជាអនីតិសង្វាសរបស់ នាងខ្ញុំ ដោយក្តីអនុគ្រោះ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០១៤
ស្នាមមេដៃស្តាំ

អ៊ឹង ដាណែត

៤–ពាក្យបណ្ដឹងរបស់
ពលរដ្ឋចំនួន ១៦៦ គ្រួសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យបណ្ដឹង

ដើមចោទ: យើងខ្ញុំទាំងអស់គ្នាជាម្ចាស់ដី មានទីតាំងស្ថិតនៅភូមិពោង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្ដាល។

ចុងចម្លើយ : ក្រុមហ៊ុន ស៊ីធីម៉ាត មានទីតាំងស្ថិតនៅផ្ទះលេខ ៨៤AB ផ្លូវលេខ ១៥៤ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលមានលោក Musta Amad ជានាយកក្រុមហ៊ុន។

សូមគោរពចូលមក
ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

*សូមទានជ្រាប។*

កម្មវត្ថុ ៖ សុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម :

១–សុំបដិសេធចោលវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ក្រុមហ៊ុន ស៊ីធីម៉ាក (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ "ក")។

២–ទទួលស្គាល់ការកាន់កាប់ដីរបស់យើងខ្ញុំទាំង ១៦៦គ្រួសារ ដែលមានទំហំ ៨១ ហិកតា មានទីតាំងស្ថិតនៅ ភូមិពោង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្ដាល។

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំសូមជម្រាប លោកប្រធាន មេត្តាជ្រាបថា : យើងខ្ញុំទាំងអស់គ្នាបានកាន់កាប់ គ្រប់គ្រង បង្កបង្កើនផលលើដី ដូចជា ដាំពោត សណ្ដែក ល្ង និងធ្វើស្រែលើផ្ទៃដី ទំហំ ៨១ហិកតា ដែលមានទីតាំងស្ថិតនៅចំណុចបឹងកក់ ភូមិពោង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្ដាល តាំងពីឆ្នាំ ១៩៧៩ មក។

ទើបមកដល់ឆ្នាំ ២០០៦ ក្រុមហ៊ុន ស៊ីធីម៉ាត បានរំលោភបំពានកាន់កាប់ដី ព្រមទាំងធ្វើប្លង់កម្មសិទ្ធិលើដីរបស់យើងខ្ញុំទាំងអស់គ្នា។ ទោះបីជាអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ មានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, រដ្ឋសភា, ព្រឹទ្ធសភា បានចេញលិខិតអន្តរាគមន៍យ៉ាងណាក៏ដោយក៏ក្រុមហ៊ុននៅតែមិនអើពើដែរ។

ដោយសារសកម្មភាពរំលោភបំពានដូចនេះហើយ ទើបយើងខ្ញុំទាំងអស់គ្នា ប្ដឹងមក តុលាការដើម្បីជួយរកយុត្តិធម៌ឱ្យយើងខ្ញុំបានកាន់កាប់ គ្រប់គ្រង និង ប្រើប្រាស់ដីវិញ។

អាស្រ័យហេតុនេះ សូម លោកប្រធាន មេត្តាចេញសាលក្រមសម្រេចតាមការស្នើសុំ ដូចមានក្នុងកម្មវត្ថុខាងលើ ដោយក្ដីអនុគ្រោះ។

សូម លោកប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ភ្នំពេញ,ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤

ស្នាមមេដៃអ្នកតំណាង